BMI0043

# សម្ភាសន៍ជាមួយឈ្មោះ ព្រាប រឿន ភេទស្រី

មុខងារសម័យខ្មែរក្រហមៈ កងចល័តតំបន់

មុខងារបច្ចុប្បន្នៈ ពេទ្យនៅមណ្ឌលសុខភាពម៉ាឡៃ

ស្រុកកំណើតនៅភូមិភ្នំរនុះ ឃុំប្រាសាទ ស្រុកគីរីវង់ ខេត្តតាកែវ

សព្វថ្ងៃរស់នៅភូមិកណ្តាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឆាយ ឈុនលី

០១:០៤:៣៨

៣៧ទំព័រ

ឈុនលី ៖ ពេលឆ្នាំ៧៥?

រឿន ៖ អាយុ១៣ឆ្នាំ ។

ឈុនលី ៖ ដំបូងគេប្រាប់ថា?

រឿន ៖ ឲ្យរើសកងកុមារ ចា៎! គេហៅកងចល័តចឹង ។

ឈុនលី ៖ កុមារគេហៅកងចល័តដែរ?

រឿន ៖ ចា៎! កងចល័ត ។

ឈុនលី ៖ ឆ្នាំ១៩៧៥?

រឿន ៖ ចា៎! ទៅនៅព្រំដែនយួនម្ខាងមាត់ជ្រូកសេកដេកនោះ ។

ឈុនលី ៖ ថាអីគេ?

រឿន ៖ ទៅត្រសេកដេកនោះ ទៅជិតស្ពឺគេហៅភ្នំស្វាមទៅទល់ដែនយួនម៉ង់នៅនឹង នៅកងកុមារទៅ ស្រែប្រាំងធ្វើអីចឹងទៅ ។

ឈុនលី ៖ ហើយអានឹងកងនឹង គេហៅកងអីគេ?

រឿន ៖ កងកុមារតំបន់ ។

ឈុនលី ៖ តំបន់អីគេ គេហៅ?

រឿន ៖ តំបន់១៣ហ្នឹង ។

ឈុនលី ៖ កាលនឹងអ្នកណាគេអ្នកគ្រប់គ្រងកងនឹង?

រឿន ៖ គ្រប់គ្រងកងធំម៉ង ឈ្មោះបងវណ្ណា ។

ឈុនលី ៖ ស្រី ប្រុស?

រឿន ៖ ស្រី ។

ឈុនលី ៖ វណ្ណា?

រឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ហើយចឹងការងារមីងធ្វើ?

រឿន ៖ ធ្វើធម្មតាចឹងទៅ ខែច្រូតៗ ខែស្ទូងៗ ។

ឈុនលី ៖ យើងកុមារ គេឲ្យទៅច្រូតដែរ?

រឿន ៖ ច្រូត សុទ្ធតែនេះ សុទ្ធវាស់កុងច្រូត ម៉ាកុង៤០ម៉ែត្រ៤ជ្រុង គេឲ្យច្រូតហើយមុនគេ ឈប់មុនគេ ។

ឈុនលី ៖ ហើយបន្ទាប់ពីនឹងហើយទៀត ផុតពីកងកុមារធ្វើអី?

រឿន ៖ បន្ទាប់ពីកងកុមារនឹង គេឡើងឆ្នាំ៧៧ មីងគេរើងមកបាត់ដំបង ។

ឈុនលី ៖ រើសមកបាត់ដំបងនឹងដើម្បីអីគេ?

រឿន ៖ មិនដឹងដើម្បី បើគេថាឲ្យមកខ្លះនៅកាត់ដេរចឹង ខ្លះនៅរោងចក្រចឹងទៅ ។

ឈុនលី ៖ រោងចក្រនៅបាត់ដំបងនឹង?

រឿន ៖ ចា៎! ដល់មីងមកមីងធ្វើស្រែ ។

ឈុនលី ៖ មកនៅបាត់ដំបងនៅស្រុកអី?

រឿន ៖ នៅតំបន់៥ នៅម្តុំវាលទ្រា ធ្វើកងចល័តដដែល ។

ឈុនលី ៖ សព្វថ្ងៃគេហៅស្រុកអីគេ?

រឿន ៖ បាត់ដំបងមិនដឹងស្រុកស្អីគេ ស្រុកវាលទ្រាដឹង ស្រុកអីខ្ញុំអត់ដែលស្គាល់ដែលឥឡូវ ។

ឈុនលី ៖ អត់ដែលទៅនឹង?

រឿន ៖ អត់ដែលទៅៗលេងខាងម៉ែក្មេកនៅថ្មគោលម្តងម្កាល ។

ឈុនលី ៖ នៅជិតថ្មគោល?

រឿន ៖ នៅជិតដែរ ។

ឈុនលី ៖ ឃុំមីងស្គាល់ឃុំអី?

រឿន ៖ ទេ! ពីមុនមិនដឹងឃុំអីគេហៅម្តុំវាលទ្រាៗ មីងក៏មិនដែលដឹងដែរ អត់ដែលដឹងទេ ។

ឈុនលី ៖ ចឹងខ្ញុំចង់សួរមីងកន្លែងកងមីងនៅនឹង គេហៅឃុំអី កាលមីងនៅតាកែវ?

រឿន ៖ ខ្ញុំនៅតាកែវ ខ្ញុំនៅឃុំអង្គប្រាសាទ អូ!ទៅនៅខាងនោះ ។

ឈុនលី ៖ ពេលនៅកង?

រឿន ៖ នៅកងអត់មានឃុំទេ នៅស្រុកកោះអណ្ដែតហ្នឹងម៉ង ។

ឃុនលី ៖ ខេត្តអី?

រឿន ៖ ខេត្តតាកែវដដែល ។

ឃុនលី ៖ ដែលមីងថានៅជាយដែននឹង?

រឿន ៖ ចា៎! នៅជាយដែននឹងគេហៅកងកុមារ ។

ឃុនលី ៖ គ្នាច្រើនទេកាលនឹង?

រឿន ៖ ច្រើនណាស់ មនុស្សរាប់ពាន់ទាំងស្រីទាំងប្រុសក្មេងៗចាស់ៗដូចថាក្រមុំកម្លោះគេ ហើយនឹងកុមារតូចៗ ។

ឃុនលី ៖ ហើយចុះដល់ពេលមកដល់បាត់ដំបងនឹង គេឲ្យយើងធ្វើអីគេខ្លះ?

រឿន ៖ បាត់ដំបងខ្ញុំធ្វើស្រែ នៅកងចល័តដែរ ។

ឃុនលី ៖ ដកស្ទូង?

រឿន ៖ ចា៎! ដកស្ទូងដដែល ។

ឃុនលី ៖ កាលនឹងគេហៅខេត្ត ឬមួយគេហៅតំបន់?

រឿន ៖ គេហៅតំបន់ ។

ឃុនលី ៖ ជំនាន់នឹងគេហៅតំបន់អីគេ?

រឿន ៖ តំបន់ពីនោះមក ។

ឃុនលី ៖ មកដល់បាត់ដំបងហើយ?

រឿន ៖ តំបន់៥ ។

ឃុនលី ៖ មីងដឹងថាអ្នកណាគេដឹកនាំតំបន់៥?

រឿន ៖ ជំនាន់នោះមក កាលនោះគេថាតាញឹមក្បត់មេ៉ចម៉ាទេ មីងមិនសូវដឹងដែរ នៅតូចៗដែរ មិនទាន់ដឹងអីច្បាស់ផង គេថាតាញឹមក្បត់ យកតាម៉ុកមកកាន់ខាង... ប៉ុនតាម៉ុកនឹងឮឈ្មោះ ។

ឃុនលី ៖ អត់ដែលឃើញ?

រឿន ៖ ចា៎! អត់ដែលឃើញ ឮតែឈ្មោះមិនដឹងនៅណានៅណោឮតែគេនិយាយ មិនដែលដឹងដែរ ។ ដល់មីងមកនៅនឹងចេះនៅនឹងគេនឹងឯងចឹងទៅ ។

ឃុនលី ៖ ចឹងកាលនឹងគេហៅកងអី?

រឿន ៖ កងចល័តដូចគ្នា ចល័តតំបន់៧៥ ។

ឃុនលី ៖ កាលនឹងមីងអាយុប៉ុន្មាន ១៥នៅ?

រឿន ៖ ១៥ហើយ អាយុ១៥ហើយ ។

ឈុនលី ៖ ចុះអ្នកដឹកនាំនៅក្នុងកងចល័តរបស់មីងៗស្គាល់ទេ?

រឿន ៖ ស្គាល់តើ ។

ឈុនលី ៖ គាត់ឈ្មោះអីគេ?

រឿន ៖ ឈ្មោះ បងខឿន ស្រី ។

ឈុនលី ៖ ឥឡូវគាត់នៅរស់ដែរ?

រឿន ៖ ទេ! មិនដឹងទៅណាណៃបែកអស់ ខ្ទេចខ្ទីអស់ មិនដឹងទៅណា យើងរត់៧៩ ដឹងគាត់ទៅណាទៅណៃ ។

ឈុនលី ៖ ចុះដល់ពេលនៅកងចល័តនឹងហើយម៉េចទៀតទៅ?

រឿន ៖ អត់មានម៉េចទេ ធ្វើការធម្មតាធ្វើស្រែស្ទូងៗចឹងទៅ ពេលច្រូតៗទៅ រស់នៅដូចគេដូចឯងចឹងដែរ អត់មានដែលលំបាកអីផង ។

ឈុនលី ៖ ហើយដល់ពេលក្រោយមកយើងរត់មក៧៩?

រឿន ៖ ចាំ! យើងរត់ ។

ឈុនលី ៖ មីងដឹងទេមូលហេតុអីបានរត់មកតំបន់ហ្នឹង?

រឿន ៖ ទេ! កាលនឹងគេថាយួនចូលៗ គេឲ្យរត់មកចេះនាំគ្នារត់ទៅ ។

ឈុនលី ៖ ហើយរត់មក ហេតុអីបានរត់មកតំបន់នឹង ម៉េចអត់ទៅតំបន់ណាផ្សេងទៀត?

រឿន ៖ មាន មិនដឹងម៉េច ពួកគេថាទៅលិចៗ ចេះមកនឹងគេកាត់ព្រៃកាត់ស្រុកត្រែង ។

ឈុនលី ៖ គេប្រាប់មកថាទៅលិច?

រឿន ៖ ចាំ! គេឲ្យទៅលិច គេចកុំឲ្យយួនចាប់ ។ មីងរត់ទៅដល់ពោធិ៍សាត់ ថាទៅស្រុកវិញ ដល់ទៅដល់នោះ ស្រាប់តែតាម៉ុកថាអត់ឲ្យរត់ទៅកើតទេ ឲ្យមកលិចវិញ ។

ឈុនលី ៖ តាម៉ុកអ្នកថាចឹង?

រឿន ៖ គាត់ជិះឡានយោធាគាត់ច្រើននោះ គាត់ថាកុំទៅកើត ឲ្យមកលិច ។

ឈុនលី ៖ គាត់ស្រែកប្រាប់យើងផ្ទាល់?

រឿន ៖ ចាំ! ប្រាប់តើ ។

ឈុនលី ៖ មីងឃើញ?

រឿន ៖ ឃើញៗគាត់ចុះមកប្រាប់ គាត់ថាកូនៗកុំឲ្យទៅកើតៗយួនចាប់ហើយអស់ដីនៅឲ្យមកលិចមក ក៏ចេះរត់តាមមកលិចទៀត ។ មានទ័ពគេជូន គេដឹងផ្លូវ គេជូនទៅគេជិះសេះនាំមកមុនមកហើយយើងចេះដើរមកក្រោយមានឡានចឹង មានរទេះគោ មានដើរចឹង ចេះមកតាមនឹងគេនឹងឯង រត់កាត់គ្រាប់ប្លោងរត់កាត់អី ។

ឈុនលី ៖ ហើយដល់ពេលរត់មកលិចនឹង មកតាមផ្លូវណាវិញ?

រឿន ៖ មកលិចនឹង មកពីពោធិ៍សាត់វិញ មកដល់អូរដារ មកដល់ចឹង មកផ្លូវជាតិលេខ១០ ។

ឈុនលី ៖ អូរដាៗណា?

រឿន ៖ អូរដាទៅខាងផ្លូវទៅប៉ៃលិនចេះ ។

ឈុនលី ៖ ពោធិ៍សាត់នឹងទៅដល់ស្រុកណាហើយ?

រឿន ៖ ពោធិ៍សាត់ដល់ស្ទឹងលាចម៎ង ប្រុងឆ្លងទៅហើយ ។

ឈុនលី ៖ ស្ទឹងលាច គេហៅស្ទឹងក្បាល៣?

រឿន ៖ ហា៎!មិនដឹងម៉េចទេ ដឹងគេហៅស្ទឹងក្បាល៣ដឹងអីម៉េចទេ ប៉ុនគេហៅស្ទឹងលាច ទៅដល់ស្ទឹងលាចនឹងហើយ ។ តែមកវិញនឹង រត់តាមផ្លូវគេកោះក្រឡកោះអី ចេះកុងមកតាមផ្លូវជាតិលេខ១០នឹងមកឡើងមកផ្លូវប្រដាក់៤ផ្លូវនេះ ។

ឈុនលី ៖ កាត់តាមអូរដាទៀត?

រឿន ៖ ចា៎! គ្រប់ក្រឡោះក្រលាគអស់ហើយ មកតាមប្រដាក់បួនផ្លូវនេះបានមកព្រៃធំៗ បានចេញមកតាមស្ទឹងដីសស្ទឹងអីណាខ្ញុំមិនស្គាល់ដែរ ចេះតាមគេ ចេះតែមកៗ ។

ឈុនលី ៖ ហើយពេលមកនឹងគ្នាច្រើន?

រឿន ៖ ច្រើន ។

ឈុនលី ៖ មានប្រជាជន មានទ័ពអីចឹង?

រឿន ៖ ប្រជាជន ទ័ពមុខចឹងវហូត ប្រជាជនចឹង មានឡានមានអីទ័ព ដល់ប្រជាជនមានរទេះគោមានដើរចឹងទៅ ។ ជួនកាលក៏មកដល់ ពួកខ្ញុំកំពុងដាំបាយហូបជាមួយប្រជាជន មានអីគ្រាប់ប្លោងមកក៏រត់ទៀតទៅ ចូលព្រៃឫស្សីចូលអីចឹង វេទនាណាស់ អត់មានទឹកហូបទេ ស្លាប់ក៏ស្លាប់ ជួនកាលចូលទៅចេញអត់រួចទេព្រៃឫស្សី វាខែននោះនៅស្លាប់ក្នុងនឹង ។

ឈុនលី ៖ ហ្នឹងនៅក្នុងខេត្តពោធិ៍សាត់នៅឡើយ?

រឿន ៖ អត់ទេ នៅបាត់ដំបងនេះ ។

ឈុនលី ៖ អានឹងស្រុកអីគេ?

រឿន ៖ ស្រុកដែលស្អីគេនេះ ស្រុកនេះខាងនេះបាត់ដំបង ស្រុកបវេលនេះឯងមកវេទនានេះខ្លាំង រត់គ្រាប់ប្លោង ។

ឈុនលី ៖ ចឹងពេលរត់មកនឹង គេមានដូចថាអ្នកគ្រប់គ្រងគេទាំងមូលមកតាមជាមួយដែរ?

រឿន ៖ មកតើ អ្នកគ្រប់គ្រង ។

ឈុនលី ៖ អ្នកណាគេដែរ?

រឿន ៖ អានឹងរត់នឹង ខ្ញុំមកនៅជាមួយគេតាមសហករណ៍ហើយ ។

ឈុនលី ៖ ពេលនឹងមកនៅសហករណ៍ទៀត?

រឿន ៖ ចាំ! នៅតាមសហករណ៍ រត់តាមមីង ហើយយើងអត់ហ៊ាននៅតែឯងខ្លាចអត់អីហូបនោះ ។

ឈុនលី ៖ អានឹងឆ្នាំ៧៩ហើយ?

រឿន ៖ ៧៩ដែរត់នឹង ។

ឈុនលី ៖ ខែណា មីងចាំទេ?

រឿន ៖ ហី! ដឹងខែណាទេ ខែច្រូតខែណា ខែ១១ ១២ដឹង ច្រូតស្រូវទុំដំបូងខែ១១ហ្នឹងឯងស្រូវម្ទិះ ហើយក៏ម៉េចទេ ។

ឈុនលី ៖ ពេលនឹងវៀតណាមចូលដល់ភ្នំពេញឥឡូវ?

រឿន ៖ ទម្លាក់កាប៉ាល់ហោះឆេះសាំងនៅបាត់ដំបងហើយនឹង ពួករត់នឹង ពេលទម្លាក់ពីលើកកាបាល់ហោះឆេះសាំងមើលទៅឃើញឡើងខ្មៅងងឹត ។ បានប្រធានឃុំ ប្រធានស្រុកគេថា ឲ្យបងប្អូននាំគ្នាជម្លៀសខ្លួនពីភូមិពីឃុំទៅ ។ បានប្រជាជនចាប់រទេះចាប់អីទៅដាក់ស្រូវ ដាក់អង្ករមក ខ្ញុំក៏មកជាមួយប្រជាជនតាមទៅទៀតទៅ ។

ឈុនលី ៖ ចៅហ្វាយស្រុកនឹង ចៅហ្វាយស្រុកខាងតាកែវនឹង?

រឿន ៖ អត់ទេ ចៅហ្វាយស្រុកមកនៅបាត់ដំបងនេះ ។

ឈុនលី ៖ ចឹងបានន័យថាមីងរត់៧៩ហើយ?

រឿន ៖ ពីឆ្នាំ៧៧មីងមកៗនៅនឹងបាត់ដំបងនឹង ហើយដល់រត់មិនរត់ចេញពីបាត់ដំបង ។

ឈុនលី ៖ ចាំ! យល់ហើយ ចឹងកាលនឹងចៅហ្វាយស្រុកអ្នកណាគេទៅ?

រឿន ៖ ចៅហ្វាយស្រុកមិនដឹងឈ្មោះអីទេ ដូចភ្លេចចៅហ្វាយស្រុកភ្នំសំពៅនឹង ។

ឈុនលី ៖ កាលនឹងស្រុកភ្នំសំពៅ?

រឿន ៖ ចាំ! ស្រុកភ្នំសំពៅ មីងភ្លេចហើយប្អូនអើយ យូរហើយភ្លេចឈ្មោះ ចាំតែមេឃុំ ។

ឈុនលី ៖ មេឃុំគាត់ឈ្មោះអី?

រឿន ៖ មេឃុំគាត់ឈ្មោះមូល ។

ឈុនលី ៖ ត្រកូលគាត់អីគេ?

រឿន ៖ ហ៊ឺ! អត់ដឹងទេ អត់ដឹងត្រកូលឈ្មោះអី មីងអត់ចាំ ប៉ុនដឹងកន្លែងគ្រប់គ្រងកន្លែងមីង ស្រីនឹង គាត់លេខាដែរ ឈ្មោះរឿនដែលមកពីស្រែអំបិល តែមិនដឹងត្រកូលគាត់ឈ្មោះអីដែរខ្ញុំអត់សួរចាំដែរ ។

ឈុនលី ៖ ហើយចុះដល់ពេលរត់មកអីចឹង ចាញ់ទេ ចាញ់ខ្លាំង?

រឿន ៖ ចាញ់ មីងស្មានតែមិនរស់ផង មីងឈឺមកមិនដល់តំបន់នេះអគ្គការគាកបាទក្រហមនឹង ដឹកយកទៅជំរំៗអើយស្រះកែវ ។

ឈុនលី ៖ ជំរំស្រះកែវនៅខាងណាវិញ?

រឿន ៖ ជំរំស្រះកែវជិះឡានទៅចេះទៅផ្លូវអារញ្ញ មិនដឹងណាទេ ។

ឈុនលី ៖ នៅដីថៃ?

រឿន ៖ ដីថៃជ្រៅណាស់ ។

ឈុនលី ៖ ចុះមិនមែនជំរំ៨៥ទេ?

រឿន ៖ ហ៉េ! ៨៥នឹងក្រោយមកទេៗដែលមីងចូលជំរំស្រះកែវនឹងរត់ចេញពីដីយើងចូលមកដីថៃ គេយកទៅជំរំស្រះកែវៗចឹងទៅ គេបកយកមកវិញថា គេហៅទៅសួរថាប្រធានជំរំថាបងប្អូនណាជាមួយបារាំងអីនឹងគឺបងប្អូនណាទៅខ្មែរវិញ គេកត់ឈ្មោះទៅខ្មែរ អ្នកណាទៅបរទេសៗតែចឹងគេសួរមីង ហើយគេសួរទៅនៅម្នាក់ឯង ខ្ញុំនៅជាមួយមីងៗដូចប្រជាជនចឹងដែរ ។ សួរខ្ញុំថាអត់ទៅគ្រាវទៅអីទេណាទេ ខ្ញុំអត់ហ៊ានទៅខ្លាចបែកម៉ែបែកឪ ។ ចុះនៅតូចដែរ នៅ ១៥ ១៦ឆ្នាំ ខ្លាចបែកម៉ែបែកឪខ្ញុំមកស្រុកវិញហើយ ខ្ញុំអត់ទៅទេ ។ ហើយដល់ចឹងគេដាក់នៅស្រុកគេដឹកយកមកដាក់ចំការចេក តំបន់ខ្មែរក្រហមនេះដដែល ។

ឈុនលី ៖ ចំការចេក?

រឿន ៖ ចា៎! ចំការចេក ឥឡូវគេហៅម៉ុំគីឡូ១៣ ។

ឈុនលី ៖ ក្នុងស្រុកអីគេ?

រឿន ៖ ស្រុកសំពៅលូន ។

ឈុនលី ៖ ចុះមីងថាពេលដែលឈឺនឹង អានឹងក្នុងឆ្នាំណាដែលគេដឹកយកទៅជំរំ?

រឿន ៖ ៧៩ ។

ឈុនលី ៖ ពេល?

រឿន ៖ ពេលយើងចូលរត់ចូលមលម៉ង ។

ឈុនលី ៖ ហើយមានអ្នកឈឺច្រើនទៀតទេ?

រឿន ៖ អូ! ពេញៗឡាននិយាយពីចាញ់ យកទៅបារាំងមើល គេដាក់តង់វែងខ្លះក៏ស្លាប់ទៅខ្លះក៏រស់ទៅ តែទៅដល់គេចុះ គេឲ្យហូបទឹកដោះគោ ហើយអ្នកខ្លះរាគៗក៏ស្លាប់ទៅ ។ ប៉ុនគេរាគ គេដាក់សារ៉ូ បើអ្នកខ្លះក៏ជាវិញទៅ ។ ប៉ុនភាគច្រើនគឺស្លាប់ដែលរត់ជំនាន់នឹង ។

ឈុនលី ៖ ព្យាបាលយូរទេ ពេលដែលមីងទៅហ្នឹង?

រឿន ៖ យូរដែរ ជិតកន្លះខែ ។

ឈុនលី ៖ ប៉ុន្តែក្នុងឆ្នាំ៧៩វិញ?

រឿន ៖ ចា៎! ៧៩ ដល់ត្រឡប់មកនេះវិញឆ្នាំ៨០ ។

ឈុនលី ៖ ហើយដល់ពេលត្រឡប់មកវិញធ្វើអីទៀត?

រឿន ៖ ពេលត្រឡប់មកវិញ ខ្ញុំនៅជាមួយមីងនេះប្រជាជនដដែល ដល់ហើយភូមិដូងនេះ គាត់ថាខ្វះបុគ្គលិក គាត់ជ្រើសរើស ដល់ហើយគ្នាខ្ញុំ៥នាក់នឹង ក៏ពូជន គាត់ទទួលខុសត្រូវកន្លែងនឹង ថាឥឡូវពួក៤-៥នាក់នឹងទៅនៅពេទ្យភូមិដូងទៅ អ៊ីធន់គាត់រកពេទ្យ ។ ដល់ចឹងធ្វើប្រវត្តិរូបធ្វើអីហើយ ក៏គាត់ឲ្យមកនៅពេទ្យភូមិដូង កាលនឹងគេហៅពេទ្យ១០២ ។

ឈុនលី ៖ ហ្នឹងឆ្នាំណា?

រឿន ៖ ឆ្នាំ៨០ ។

ឈុនលី ៖ ៨០?

រឿន ៖ ចា៎!

ឈុនលី ៖ ចុះពេលនឹងដូចថាមកដំបូងចឹង វាមានព្រៃមានអីទេ?

រឿន ៖ អូ! ព្រៃអត់មានថ្ងៃទេ មើលថ្ងៃអត់ឃើញទេ ខោអាវហាលអត់ស្ងួតទេ ហើយក្រោមចេះកុំបត់ជើងផ្តេសផ្តាស់ សត្វទាច ហើយឈើងនោះអត់បានទេ វាខាំក្រលាន ខាំគៀនកោះណាលោតទុំព្រៃៗច្រើនណាស់ ហើយចាញ់ក៏ចាញ់ដែរ ។

ឈុនលី ៖ ចឹងយើងនៅម៉េច?

រឿន ៖ នៅដូចថាធ្វើរោងដាក់ឫស្សីខ្ពស់ៗចឹងចេះនាំគ្នានៅ ធ្វើឈើធ្វើរោង ធ្វើគ្រែអីនៅ ។

ឈុនលី ៖ ចុះមីងថានៅសហករណ៍ នៅនឹងមានសហករណ៍ដែរ មីងថានៅណា...ដែលមីងថានៅជាមួយមីងៗ?

រឿន ៖ នៅជាមួយមីងៗមកមានរត់មកដូចគ្នាចឹង មីងៗនៅតាមគ្រួសារគាត់ដូចថាគាត់ចេះរកស៊ីអីផ្សេងមកចេះនៅតាមនក្រុមគ្នា ។ ដល់មីងគេរើសពេទ្យនៅ១០២ក៏មីងបែកពីនឹងមក ។

ឈុនលី ៖ សហករណ៍គេនឹងគេរស់នៅម៉េចទៅ ដូចពីមុនទេ?

រឿន ៖ អត់ដូចទេ ហូបតាមផ្ទះយើង ប៉ុនដូចថានៅតាមក្រុមនៅតាមកង ពីមុនមកយើងធ្លាប់នៅកាលយើងរត់យួននៅនោះមកនោះ ចេះនៅជុំគ្នាដែរ ។

ឈុនលី ៖ ចុះអានឹងគេហៅសហករណ៍អីគេ?

រឿន ៖ សហករណ៍នៅសហករណ៍នៅភ្នំសំពៅ ។

ឈុនលី ៖ គេហៅសហករណ៍ភ្នំសំពៅ?

រឿន ៖ ចា៎! ចេះនៅជុំគ្នាចឹង ។

ឈុនលី ៖ គ្នាច្រើន?

រឿន ៖ ហ៊ើ! ច្រើនដែរ ប៉ុនរត់មកនឹងប្រហែលជា៥០-៦០គ្រួសារ ដល់ហើយវាបែកគ្នាអស់ទៅ ខ្លះគេទៅក្រៅចឹងទៅ ។

ឈុនលី ៖ ៥០-៦០គ្រួសារ?

រឿន ៖ ចា៎! ខ្លះគេមកខ្លះអត់មកគេរត់ ។

ឈុនលី ៖ អ្នកណាអ្នកដឹកនាំសហករណ៍?

រឿន ៖ សហករណ៍ខ្ញុំប្រាប់គាត់មិញ តាមូលនឹង គាត់ដឹកនាំរហូតទាល់នៅជំរំទល់នៅនេះ ។

ឈុនលី ៖ គាត់ធ្វើមេឃុំ ហើយគាត់ធ្វើសហករណ៍?

រឿន ៖ ចា៎! គាត់នៅទទួលខុសត្រូវ មេឃុំគេហៅប្រធានសហករណ៍ ។

ឈុនលី ៖ ហើយសហករណ៍នឹងកាលនឹងដូចថាហូបចុកអីគ្រប់ទេ?

រឿន ៖ ហូបគ្រប់ ១ថ្ងៃ៣ដង ។

ឈុនលី ៖ ហូបបាយហូបបបរ?

រឿន ៖ ហូបបាយ ពេលព្រលឹមឡើងបបរ ថ្ងៃបាយហូបធម្មតា ។

ឈុនលី ៖ ហើយចុះដល់ពេលមឹងមកនៅនេះដំបូង ចឹងមានគ្នាតែប៉ុន្មាននាក់?

រឿន ៖ គ្នាច្រើនដែរ ។

ឈុនលី ៖ មានពេទ្យនៅនេះ?

រឿន ៖ មានពេទ្យដែលយើងរត់មកនោះ រត់មកពីភ្នំពេញចឹងទៅ គាត់ទៅដាក់នៅកន្លែងនេះដូចសង្គ្រោះមានអ្នករបួស អ្នកឈឺអីចឹង ដល់ហើយគាត់រើសថែមទៀតៗ ចេះមករៀននៅធ្វើនៅនឹងបានចេះខ្លះ ។

ឈុនលី ៖ ហ្នឹងគេហៅពេទ្យអីទៅ?

រឿន ៖ ពេទ្យ១០២ ។

ឈុនលី ៖ ពេទ្យ១០២?

រឿន ៖ ចា៎!

ឈុនលី ៖ ចុះកាលនឹងអ្នកណាអ្នកមេពេទ្យអីចឹង?

រឿន ៖ ប្រធានពេទ្យ ប្រធានគ្រប់គ្រងនៅកន្លែងពេទ្យនេះឈ្មោះ ផន ។

ឈុនលី ៖ ពូផន?

រឿន ៖ ចា៎!

ឈុនលី ៖ ត្រកូលគាត់អីគេ?

រឿន ៖ អត់ដឹងត្រកូលគាត់អីទេ ពូផន ។

ឈុនលី ៖ ចឹងមីងថាពេលដដំបូងនឹងមានតែ៩នាក់ ពេទ្យនឹង?

រឿន ៖ ពួកខ្ញុំមកពីចំការចេកនឹង៩នាក់ ហើយពេទ្យគេនៅនេះគ្នាច្រើនដែរ តែវាខ្វះ ដល់ដូចថាយើងសង្រ្គាមវៃគ្នារបួសច្រើន ដល់ចឹងខ្វះអ្នកជួយលាងរបួស ខ្វះអ្នកជួយធ្វើបាយធ្វើអីចឹង គេរើសមកពីនឹងមក ពួកខ្ញុំមកនៅនឹងទៀតមក ។

ឈុនលី ៖ ហើយគេវៃគ្នានឹង គេវៃគ្នានៅណា?

រឿន ៖ ទេ! ពូតែស្នូរមិនដឹងគេវៃគ្នានៅណា ពូសូរកាំភ្លើងដែរ មីងមិនដែលទៅដល់ផង ។

ឈុនលី ៖ ចឹងមីងអ្នកដូចថាព្យាបាលអ្នកជម្ងឺអី?

រឿន ៖ ចា៎!

ឈុនលី ៖ ប៉ុន្តែដូចស្ងួតែព្រៃចឹង ចាញ់ផងអីផង?

រឿន ៖ ចា៎! គ្រូនចាញ់ ពេទ្យក៏ឈឺ ទ័ពក៏ឈឺ ប្រជាជនក៏ឈឺដូចគ្នា ឈឺពេញៗអគារ ។

ឈុនលី ៖ និយាយទៅបើគិតក្នុងកំឡុងពេលនឹង ដូចថាលំបាកខ្លាំងទេ?

រឿន ៖ លំបាកដែរនឹង លំបាកប្អូនអើយ បើឈឺនិយាយពីដាច់បាយដាច់ម៉ាអាទិត្យអីសន្ធំអត់ដឹងខ្លួនផង ។

ឈុនលី ៖ សន្ធំ?

រឿន ៖ ចា៎! សន្ធំចុះបូក៣បូក៨ហើយ វីរ៉ាក់ម៉ាស៊ីប្រូ គ្រូនចាញ់ស្លាប់ក៏ស្លាប់ទៅ ។

ឈុនលី ៖ កាលនឹងស្លាប់ច្រើន?

រឿន ៖ ស្លាប់ច្រើនណាស់ ។

ឈុនលី ៖ បើគិតដូចថាស្លាប់ប៉ុន្មានភាគរយទៅ?

រឿន ៖ ហ៎! ដូចថា១០០អីចឹង អាចត្រឹមថា៦-៧អីចឹង ។

ឈុនលី ៖ ១០០នាក់ សល់៦-៧?

រឿន ៖ ចា៎! ស្លាប់ ។ ប៉ុន្តែក្រោយ កាលនឹងយើងអត់ទានមានជំនួយទេ ដល់ជំនួយកាកបាទមកដល់ឲ្យយើង កាកបាទនៅជួយថ្នាំពេទ្យ ជួយអង្ករទឹកត្រី ។ ជំនាន់ដែលពួកខ្ញុំនិយាយថាស្លាប់៦-៧ហ្នឹងអានឹងដែលយើងរត់មកដល់ ដែលពួកខ្ញុំត្រឡប់មកនេះ មកនៅពេទ្យ អានឹងអត់ទាន់មានជំនួយទេ ជួយអត់ទាន់គ្រប់ ។

ឈុនលី ៖ កាលនឹងមីងដឹងថាកន្លែងអ្នកណាដែលក្តោប់ក្តាប់តំបន់នឹងទាំងអស់ម៉ង តំបន់១០២នឹង?

រឿន ៖ តំបន់១០២នឹង មានពូហុង ។

ឈុនលី ៖ ពូហុង?

រឿន ៖ អឺ!

ឈុនលី ៖ គាត់ឈ្មោះអីគេ?

រឿន ៖ ដឹងគាត់ឈ្មោះអីទេ ដឹងហៅពុហុង១ចឹង គាត់ទទួលខុសត្រូវនៅ១០២ ។

ឈុនលី ៖ ដូចអ្នកគ្រប់គ្រងតំបន់ម៉ង?

រឿន ៖ ចា៎! តំបន់១០២ហ្នឹង ។

ឈុនលី ៖ ទាំងទ័ពទាំងអី?

រឿន ៖ ទាំងទ័ពទាំងប្រជាជន ទាំងពេទ្យទាំងអស់ ។

ឈុនលី ៖ ចុះលោកសុខ ភាព?

រឿន ៖ ពូភាពនឹងខាងទាហាន ខាងទ័ពនោះ ។

ឈុនលី ៖ ចឹងបានន័យថាពូភាព ហើយនឹងពូហុងនឹងមួយណាធំជាង?

រឿន ៖ យី! ខ្ញុំអត់ដឹងមួយណាធំជាង ដូចថាលោកសុខភាព គាត់ខាងទ័ពលើគាត់ម៉ង ។

ឈុនលី ៖ អានឹងកងពល៤៥០?

រឿន ៖ កងពល១០២១ពីមុនគេហៅ១០២ ។

ឈុនលី ៖ ចុះ៤៥០?

រឿន ៖ អត់ដឹងពីណាទេ៤៥០ ប៉ុន្តែពីមុនលោកសុខ ភាព គ្រប់គ្រងនៅកន្លែងនឹង១០២ នៅលើគាត់ ។

ឈុនលី ៖ ហើយដល់ពេលពូហុងនឹង?

រឿន ៖ ពូហុងនឹងគេហៅស្ទីម៉េចទេ ។

ឈុនលី ៖ របៀបដូចថាគាត់គ្រប់គ្រងរួម?

រឿន ៖ រួមទាំងអស់ ។

ឈុនលី ៖ ចឹងបានន័យថាគាត់ធំជាងពូភាព?

រឿន ៖ គាត់ធំ ពូហុងធំជាង ។

ឈុនលី ៖ ធំជាងទៀត?

រឿន ៖ ចា៎!

ឈុនលី ៖ ព្រោះគាត់ក្តោបក្តាប់ទាំងអស់?

រឿន ៖ ទាំងអស់ ម៉ាតំបន់ហើយ ។

ឈុនលី ៖ បើគិតទៅគាត់ដូចថាក្រោមអ្នកណាទៀត ពូភាព?

រឿន ៖ ដីឥក្រោមពីណាទៀតទេ មីឥអស់សួរដីឥដែរ ប៉ុនដីឥច្បាស់ថាពូហុឥគំបន់១០២នេះ ដីឥថាពូហុឥ តែរៀនសូត្រអីឃើញតែគាត់រៀននឹឥឯឥ ហើយបើខាឥយោធាពូភាព ។

ឈុនលី ៖ មីឥនៅធ្វើពេទ្យដល់ឆ្នាំណាទៀតទៅ?

រឿន ៖ មិនដឹងឆ្នាំណា ដល់ថ្ងៃចប់រឺត្រែម៉ឹង?

ឈុនលី ៖ អាត្រែពេលណា?

រឿន ៖ ៥៥ ឥឡូវនៅ២ឆ្នាំទៀតចប់ ។

ឈុនលី ៖ ឥឡូវចុះសព្វថ្ងៃមីឥធ្វើអី?

រឿន ៖ នៅកន្លែឥពេទ្យហ្នឹឥដែរ នៅមណ្ឌលសុខភាពម៉ាខ្សែ ។

ឈុនលី ៖ មីឥដូចថាមីឥមានបានជម្លៀសទៅខាឥ៨៥នឹឥគេ?

រឿន ៖ ទៅ ។

ឈុនលី ៖ អានឹឥទៅឆ្នាំណា?

រឿន ៖ ចាំ! អានឹឥពីដែលមកនេះម៉ាសារចឹឥ ខ្ញុំម៉ាសារមកធ្វើផ្ទះធ្វើអីបានធម្មតា អានឹឥឆ្នាំ៨២ ខ្ញុំការហើយបានកូនមួយរត់ទៅនៅ៨៥វិញ ។

ឈុនលី ៖ ការជាមួយពូនៅ គាត់នៅធ្វើអី?

រឿន ៖ ចាំ! ពូនៅកន្លែឥមន្ទីរក្នុឥកឥការពារភ្ញៀវ ។

ឈុនលី ៖ កឥការពារភ្ញៀវ អានឹឥគេធ្វើរបៀបម៉េចវិញ មន្ទីរនឹឥ?

រឿន ៖ នៅមន្ទីរផ្ទះម៉ាកន្លែឥចឹឥទៅ ដូចថាពេលមានស្តេចមានអីមកនៅកឥការពារចឹឥទៅ ។

ឈុនលី ៖ អានឹឥគេហៅសារតាំឥនឹឥ?

រឿន ៖ ចាំ! សារតាំឥ ។

ឈុនលី ៖ ចឹឥគាត់ធ្វើការនៅនឹឥ?

រឿន ៖ ចាំ! គាត់នៅនឹឥ ហើយខ្ញុំនៅពេទ្យនេះ ។ ដល់ចឹឥទៅ ខ្ញុំការហើយធ្វើផ្ទះបានកូនមួយមីបឥនោះរត់ទៅនៅ៨៥ម៉ាសារទៀត ។

ឈុនលី ៖ ហេតុអីបានរត់ទៅ?

រឿន ៖ យួនវ៉ៃទៀត ។

ឈុនលី ៖ យួនវ៉ៃទៀត?

រឿន ៖ ហ្នឹឥហើយ យួនវ៉ៃទៀត ។

ឈុនលី ៖ ចូលទៅដល់ណា?

រឿន ៖ យួនចូលមកដល់ផ្ទះម៉ឹឥ មកដល់មន្ទីរពេទ្យ ហ្នឹឥប្លោឥធ្លាក់មុខផ្ទះខ្ញុំនៅមុខ ប្លោឥធ្លាក់ ។

ឈុនលី ៖ នៅភូមិដូននឹង?

រឿន ៖ ហ្នឹងភូមិដូននឹង ច្បាំងក្ដឹងៗ គេនាំគ្នារត់ចេញ ។

ឈុនលី ៖ ចឹងម្នាក់ៗនាំគ្នារត់ទាំងអស់?

រឿន ៖ រត់ទាំងអស់ ។

ឈុនលី ៖ រត់ទៅ៨៥?

រឿន ៖ ចា៎! រត់ទៅ៨៥ ។

ឈុនលី ៖ អានឹងឆ្នាំ៨២?

រឿន ៖ ហ៎! ៨២អី ឆ្នាំ៨៥នឹងហើយ រត់៨៥រត់ចូលដីថៃម្ដងទៀត ។

ឈុនលី ៖ ពេល៨២ ចុះមីងជាឆ្នាំ៨២?

រឿន ៖ ៨២នៅនឹង ការហើយបានកូនមួយ ៨៥នឹងរត់ម៉ាសារទៀត រត់ទៀត ។

ឈុនលី ៖ ចុះថានៅតំបន់នឹងមានមីន មានអីនោះ?

រឿន ៖ មីនច្រើនណាស់ រឿងមីនៗ ។

ឈុនលី ៖ មីននឹងចាប់ផ្ដើមមានតាំងពីពេលណា?

រឿន ៖ មីននឹងជំនាន់នឹងយើងដាក់ការពារភូមិផង ជំនាន់នឹងយើងដាក់តាំងពីយើងរត់មកនៅហើយ ទ័ពត្រឡប់ទៅដាក់វិញ ខ្លាចយួនចូលមក ។

ឈុនលី ៖ បើគិតទៅអ្នកណាអ្នកដាក់ អ្នកណាខ្លះអ្នកដាក់?

រឿន ៖ មានតែទ័ព តាំងពីជំនាន់គេការពារព្រំដែនថៃ ជំនាន់យើងនៅ៣ឆ្នាំនឹង ជំនាន់នឹងក៏ខ្មែរយើងមានទ័ពតាមព្រំដែនដាក់ខ្លាចមានគេរត់ចូលទៅថៃទៅអី ។ មីន មីងរត់មកក៏ប៉ះមីន មិនដឹងដាក់ពីជំនាន់ណាជំនាន់ណែ ។

ឈុនលី ៖ ចឹងពេលដែលមីងរត់មក មិនមានផ្ទុះមីនផ្ទុះអី?

រឿន ៖ មានៗផ្ទុះមីនតើ ។

ឈុនលី ៖ ស្លាប់មនុស្សច្រើនដែរ?

រឿន ៖ មានតើ ៗ តពូមូលប្រធានសហករណ៍មីងនឹង របួសកាលនឹងថាមិនរត់ផងរបួសមានមីនកាល នឹងដាក់ត្រឹមៗ-កម៉ង ដាក់លើដើមឈើ ។

ឈុនលី ៖ ដាក់នៅលើដើមឈើ?

រឿន ៖ ចា៎! ដាក់ដើមឈើដាក់ត្រឹម-ក អានឹងដឹងគេដាក់ជំនាន់ណាមីងអត់ដឹងដែរ ។

ឈុនលី ៖ ចុះពូមូលនឹង គាត់របួសយ៉ាងម៉េចទៅ?

រឿន ៖ របួសដើងរបួសក្បាលរបួសអីពេល ដល់ហើយគេយកទៅពេទ្យថៃ យកទៅដល់ដីថៃ ។

ឈុនលី ៖ សព្វថ្ងៃគាត់នៅរស់ដែរ?

រឿន ៖ គាត់រស់ ។

ឈុនលី ៖ គាត់នៅណា?

រឿន ៖ ទៅនៅពោធិ៍សាត់វិញ ។

ឈុនលី ៖ មកដឹងស្រុកអីទេ នៅពោធិ៍សាត់?

រឿន ៖ អត់ដឹងស្រុកទេ ដឹងថាគាត់មកលេង គាត់ថានៅពោធិ៍សាត់ៗ គាត់ប្រាប់ដែរ តែមីងមិនបាន ចាប់អារម្មណ៍ចាំទេ គាត់មកលេងគាត់ថាគាត់នៅពោធិ៍សាត់ ។

ឈុនលី ៖ ហើយដូចជាទៅនៅជំរំចឹង ពេលនឹងការរស់នៅម៉េចទៅ?

រឿន ៖ រស់នៅអត់អីទេ កាកបាទចែកអង្ករចែកអីហូបធម្មតា ។

ឈុនលី ៖ ខាងណាអ្នកចែក?

រឿន ៖ កាកបាទក្រហម មិនដឹងខាងណាហៅកាកបាទៗ ។

ឈុនលី ៖ ហើយខាងអាហារយើងគេឧបត្ថម្ភដែរអត់?

រឿន ៖ អាហារយើងនៅនេះក៏គេដឹកមកឲ្យអាហារ ។

ឈុនលី ៖ ខាងខ្មែរក្រហមយើងឧបត្ថម្ភដែរ?

រឿន ៖ ឧបត្ថម្ភ កាកបាទដឹកមកអង្ករពេញៗឡាន ។

ឈុនលី ៖ ហើយដល់ពេលណាឆ្នាំណាបានមីងត្រឡប់មកវិញ?

រឿន ៖ ដល់ឆ្នាំ៩០មិនដឹងមកវិញ ។

ឈុនលី ៖ ៩០?

រឿន ៖ ចាំ! ឆ្នាំ៩០ មកពី៨៥វិញ ។

ឈុនលី ៖ អានឹងមកនៅនឹងឈរជើងនឹងជាប់ហើយ?

រឿន ៖ ចាំ!

ឈុនលី ៖ កាលនឹងផ្ទះមីងនៅណា?

រឿន ៖ ផ្ទះខ្ញុំនៅជិតមាត់អូរដល់មកទៅចាប់រៀងខ្លួនទៅរាវមីនទៅបានមកនៅនឹង ណាផ្ទះកន្លែងណា ចាប់ ហ្នឹងរាវមីនទៅ តែចូកនឹងប៉ែល ។

ឈុនលី ៖ ចូកប៉ែល?

រឿន ៖ ចាំ! ចូកប៉ែល ចូកខ្លួនឯងទៅ ប្រុសៗចូកទៅដូចថាដងទឹកអូរចឹងដើរកន្ទេងគ្នាដូចមីប្អូនឯង ខ្ញុំ អង្គុយសិន បានកន្ទេងគ្នាទៅម៉ាសារទៀត អត់ចៀសបានទេ ដើរតាមដានប៉ែល ។

ឈុនលី ៖ ខ្លាចប៉ះមីន?

រឿន ៈ ចា៎! មិនៗ

ឈុនលី ៈ បើគិតទៅពិបាកខ្លាំង?

រឿន ៈ ពិបាក មិនៗ ដាក់យួនមកលើប្រកដែលមីនរត់ទៅនឹង យួនដាក់ខ្លាំងលើសដើម ។

ឈុនលី ៈ ពេល៨៥នឹង?

រឿន ៈ ចា៎! យួនមកដាក់នៅនឹងសុទ្ធតែមីនដាន់ហើយនឹង ។

ឈុនលី ៈចឹងតំបន់នឹងមានតែខ្មែរក្រហមហើយនឹងខាងវៀតណាម?

រឿន ៈ ចា៎!

ឈុនលី ៈ ដែលច្បាំងគ្នា?

រឿន ៈ ច្បាំងគ្នា ។

ឈុនលី ៈ បើគិតទៅខាងណាដាក់មីនច្រើនជាងគេ?

រឿន ៈ ហ៎! ខាងខ្មែរក្រហម ដាក់ជិនាន់ខ្មែរក្រហមអត់សូវប៉ុន្មានទេ ទើបយួនមកនេះដាក់ខ្លាំងម៉ង ដាក់ៗឡើងគ្មានដីទំនេរ ។ កាលមីននៅតាមនេះអត់មានមីនទេ ដល់មីងរត់ទៅនៅ៨៥នឹង មកវិញអត់ចូលអត់ចុះ ។

ឈុនលី ៈ ឆ្នាំ៩០?

រឿន ៈ ចា៎! មីនខ្លាំង ។

ឈុនលី ៈ ចុះដល់ពេលមីងត្រឡប់មកវិញចឹង ដូចជាស្ថានភាពវានៅនេះវាប្រែប្រួលម៉េចខ្លះ?

រឿន ៈ ទេ! ដូចជាធ្លាប់នៅព្រៃចឹងដូចមិនអីទេ មកចឹងបេះនៅយើងធ្វើនេះធ្វើនោះដាំដំណាំចឹងទៅ មានទឹកអូរទឹកអីបេះដងទឹកអូរហូបទៅ ។

ឈុនលី ៈ ឆ្នាំ៩០នឹង?

រឿន ៈ ចា៎!

ឈុនលី ៈ អានឹងអស់សង្គ្រាមនៅ?

រឿន ៈ អស់ហើយ ហ៎!នៅៗឆ្ងាយនៅប្រមូលទ័ពទៅ ។

ឈុនលី ៈ ចឹងបានន័យថាពេលយើងចេញពីជំរំមកនឹងវៀតណាមនឹងរត់ចេញទៅវិញខ្លះ?

រឿន ៈ ចា៎! យើងវ៉ៃដាច់ទៅវិញខ្លះហើយ ។

ឈុនលី ៈ ដល់ណាពេលនឹង?

រឿន ៈ កាលជិនាន់នឹងនៅបាត់ដំបងបាត់អីនៅវ៉ៃគ្នាតើ ។

ឈុនលី ៈ ចុះគេហៅកន្លែងខ្លាងាប់នោះ?

រឿន ៖ ខ្វាស់ាប់នឹងហើយនៅវៃក្នានៅខ្វាស់ាប់នឹងដែរ មីននៅនឹងកាំភ្លើងបាញ់កាំភ្លើងកាំភ្លើងសអីនៅសុទ្ធត្រង់សេរ នៅត្រៀមត្រង់សេរទាំងអស់ អត់មានប្រហែសទេ ។

ឈុនលី ៖ ចឹងយើងមកនឹង ដូចមីងរាវមីនរាវអីដីធំទេ សម្រាប់ដាំដំណាំ?

រឿន ៖ រាវបានម៉ាផ្ទះហ្នឹងចឹងទៅ ហើយដីកត្រង់សេរអីត្រៀម អានឹងអត់ទាន់បានធ្វើអីនៅបើករបបហូបទេ នៅជំនួយ អត់ទាន់បានធ្វើអីហូបទេ ។ ដល់ពេលយូរៗទៅដូចថាគេចេះវៃទៅ ដេញអស់ៗ ដល់ផ្ដាច់ខ្លួនទៅបានចាប់ផ្ដើមនាំគ្នាកាប់ ចំការធ្វើស្រែចំការ ។

ឈុនលី ៖ ចឹងដល់ពេលមកពីថៃវិញចឹង ពូគាត់នៅធ្វើការកន្លែងសារតាំងនឹងដដែល?

រឿន ៖ គាត់ឈប់ហើយ គាត់មកនៅអន្តភាពពេទ្យហើយ ។

ឈុនលី ៖ គាត់ធ្វើពេទ្យដែរ?

រឿន ៖ ចា៎! តាំងពីការហើយមក គាត់ឈប់ទៅនៅនឹង គាត់មកនៅនេះវិញ ។

ឈុនលី ៖ ចឹងមីងនិងពូធ្វើការជាមួយគ្នា?

រឿន ៖ ចា៎!

ឈុនលី ៖ ហើយដល់ពេលត្រឡប់មកវិញ អន្តភាពនឹងនៅតែមានដដែល?

រឿន ៖ ចា៎! នៅតែមាន ។

ឈុនលី ៖ ហើយកាលនឹងមានអ្នករបួសខ្លាំង?

រឿន ៖ របួសដល់ពេលវៃគ្នាម្ដងៗបានរបួសម្ដង៤-៥-៦ ។

ឈុនលី ៖ បើគិតទៅវៃគ្នាញឹកអត់?

រឿន ៖ ញឹកដែរនឹង ដូចថាទៅមុខទ័ពទៅមុខប៉ះគ្នាចឹងវៃគ្នាម៉ាឈុលស្ងាត់ចឹងទៅ ម៉ាថ្ងៃម្ដង ជួនកាល ២ដង ជួនកាល៣-៤ថ្ងៃចឹងទៅ វាមិនទៀង ។

ឈុនលី ៖ ហើយយើងប្រចាំការណ៍នៅពេទ្យរហូត?

រឿន ៖ ចា៎! នៅប្រចាំការណ៍នៅពេទ្យនឹង ។

ឈុនលី ៖ ហើយបន្ទាប់មកទៀត ធ្វើអីទៀត?

រឿន ៖ បន្ទាប់មកទៀត មីងអត់មានធ្វើអីទេ នៅតែចឹងទៅ ហើយធ្វើស្រែធ្វើចំការដូចសព្វថ្ងៃនឹងទៅ

ឈុនលី ៖ យើងមាន កាលនឹងអត់ទាន់ធ្វើស្រែ?

រឿន ៖ នៅទេ អត់ទាន់ធ្វើទេ មិនហ៊ានទៅណាចោលកូនទេ នៅធ្វើការតិចៗមន្ទីរពេទ្យមើលកូន ។ ម៉ោង១ម៉ោង២ដាំបាយស៊ីល្ងាចហើយខ្វាចគេច្បាំងគេអីមកទៀត ត្រៀមទុកឲ្យហើយចាននាំងចង់ទុកទាំងអស់ ។

ឈុនលី ៖ ចឹងក្រោយមកគេកាប់ឆ្ការព្រៃអីចឹងទៅ?

រឿន ៖ ចា៎! ដល់ពេលជំនាន់ផ្ដាច់ខ្លួនអ៊ុនតាក់ចូលនោះ ។

ឈុនលី ៖ ៩៣?

រឿន ៖ ចា៎! ឆ្នាំ៩៣ក៏ឲ្យចាប់ចំការរាវមីនរាវអីកាប់ព្រៃគ្រប់គ្នាទៅ ។

ឈុនលី ៖ ប៉ុន្តែអត់ទាន់ផ្ដាច់ខ្លួនទេ?

រឿន ៖ ផ្ដាច់ខ្លួនហើយ ។

ឈុនលី ៖ ផ្ដាច់ខ្លួនឆ្នាំណាវិញ?

រឿន ៖ ជំនាន់អ៊ុនតាក់៩៣នឹង គេប្រកាសផ្ដាច់ខ្លួនម៉ង ឲ្យបងប្អូនរកស៊ីឯកជនរៀងៗខ្លួននឹង ។

ឈុនលី ៖ ៩៣ ឬ៩៦?

រឿន ៖ យី! មិនដឹង៩០ប៉ុន្មានទេ មីងមិនសូវចាំដែរ ៩៦មិនដឹងអ៊ុនតាក់ចូល ។

ឈុនលី ៖ អ៊ុនតាក់ចូល៩៣?

រឿន ៖ អ៊ុនតាក់ចូលនឹងគេប្រកាសថាដែលមីងមកនឹង គេថាឲ្យរកស៊ីរៀងៗខ្លួនទៅ ដែលឥឡូវនឹងអត់មានជំនួយអីទៀតទេ ហើយក៏តាំងពីនឹងមកបែកចេះនាំគ្នាធ្វើ ។

ឈុនលី ៖ ផ្ដាច់ជំនួយហើយចឹង?

រឿន ៖ ចា៎! ផ្ដាច់ជំនួយហើយ នាំគ្នាទៅកាប់ព្រៃចឹងទៅ ធ្វើស្រែបានខ្វះចឹងចេះហូបតិចៗចេះរកចឹងដាំស្ពៃដាំៗអីលក់ចឹងទៅ ។

ឈុនលី ៖ ចុះក្រែងថាពេលផ្ដាច់ខ្លួននឹង ក្រែងមានសម្ដេចហ៊ុន សែនយាងមកដែរ?

រឿន ៖ អូ! អានឹងដល់ក្រោយ បានសម្ដេចមកក្រោយដែលនាំអំណោយ ។

ឈុនលី ៖ អានឹងគាត់មកធ្វើអី?

រឿន ៖ មកជំនួយមកអង្ករ មានមុង មានភួយមកច្រើន យកជំនួយប្រជាជន ។

ឈុនលី ៖ មកដើម្បីចែកអំណោយ?

រឿន ៖ ចា៎! ចែកអំណោយ ។

ឈុនលី ៖ មិនមែនផ្ដាច់ខ្លួនពេលនឹង?

រឿន ៖ ហ៊ា៎! មិនដឹងម៉េចទេ មីងដូចភ្លេចដែរ យូរហើយមិនបានសូវចាប់អារម្មណ៍រឿងនឹងទេ ប៉ុនផ្ដាច់ខ្លួនយូរហើយបានហ៊ុនសែនមក គាត់មិនហ៊ានមកភ្លាមៗទេ ។

ឈុនលី ៖ ចឹង?

រឿន ៖ ចា៎!

ឈុនលី ៖ ចុះគេចចារគ្នាតាំងពីអង្កាល់?

រឿន ៖ មីងមិនសូវដឹងទេប្អូនអើយ មីងមិនសូវដឹងដែរ មីងមិនដែលចាប់អារម្មណ៍រឿងចឹងៗ ។

ឃុនលី ៖ ចុះដល់ពេលក្រោយផ្តាច់ខ្លួនចឹងទៅ គេឈប់ផ្តាច់របប ឈប់មែនទែន លែងមាន?

រឿន ៖ ឈប់ហើយ លែងមាន ប៉ុន្តែដូចថាជំនាន់នៅសល់ពីមុនមក អង្ករឃ្លាំងអង្ករអីដូចថាអ្នកខ្វះចឹងទៅសុំទៅ កន្លែងសុខភាពនឹង គាត់មានអង្ករឃ្លាំងធំៗនឹង ដូចថាប្រជាជនណាខ្វះខាតចឹងគាត់ៗឲ្យៗតែទៅសុំគាត់នឹង គាត់ឲ្យ អានឹងយើងរកមិនទាន់បានៗ សុំលុយបានលុយ សុំអង្ករបានអង្ករចឹងទៅ ស្រេចគាត់ឲ្យ ខោអាវអីដូចយើងខ្វះខាត ទៅសុំគាត់ឲ្យ ពូហុងនឹងទាំងអស់គ្នាគាត់នឹងយើងទៅសុំកន្លែងណាក៏បានដែរៗ ប៉ុនដូចខ្ញុំមន្ទីរពេទ្យចឹង ច្រើនទៅកន្លែងពូហុងៗ

ឃុនលី ៖ ហើយដល់ពេលចឹងទៅ យើងធ្វើម៉េចទៅចែកដីស្រែ ដីអីគ្នា?

រឿន ៖ អត់ចែកទេ អ្នកណាចាប់បានប៉ុន្នានយកប៉ុននឹងទៅៗ

ឃុនលី ៖ ចុះកាលនឹងមីងមានដីនៅកន្លែងណាខ្លះ?

រឿន ៖ មីងមានដីប៉ុននឹង ដល់ហើយចេះទៅរកចាប់នឹងគេនឹងឯងឯព្រៃៗ

ឃុនលី ៖ ចាប់នឹងពេលណា?

រឿន ៖ ពេលឆ្នាំ៩២ ឆ្នាំ៩១ ៩២ទៅចាប់ហើយចាប់ផ្តើមធ្វើតិចៗ ដល់៩២បានលក់ទៅថៃៗ

ឃុនលី ៖ ចឹងទៅចាប់ដីនៅណាចំការ?

រឿន ៖ នៅនោះនៅភ្នំទៅក្រោយៗ ៗ

ឃុនលី ៖ ភ្នំអីគេនៅនឹង?

រឿន ៖ ភ្នំម៉ាឡៃ ភ្នំរាំង ភ្នំអី ភ្នំទឹកចេញ ភ្នំដេកាអីតាមនឹង ភ្នំវ៉ុងភ្នំអីៗ

ឃុនលី ៖ ឆ្នាំ៩២?

រឿន ៖ ចាំ! ឆ្នាំ៩២នឹងបានកាប់បានដាំរែកមកលក់ហើយ អត់មានអីដឹកទេ រែក នាំគ្នារែកៗ នាំគ្នារែកនាំគ្នាទូលពោតយកទៅលក់ឲ្យថៃៗ

ឃុនលី ៖ ហើយឈើចាប់ផ្តើមកាប់មែនទែនពេលណា?

រឿន ៖ ឈើគេអ្នកកាប់ឈើ គេកាប់ឈើតាំងពីយើងចូលមកម៉ង ចេញពីដីថៃមកវិញៗ

ឃុនលី ៖ អ្នកណាអ្នកកាប់ ទ័ព?

រឿន ៖ ទ័ព ប្រជាជនចឹង គេអ្នកកាប់ គេអ្នកលក់ អ្នករកស៊ីឈើគេកាប់ឈើទៅ តែមីងមិនដែលបានទូលមិនដែលបានធ្វើអីនឹងគេផងៗ

ឃុនលី ៖ មីងថាតាំងពីចូលមកពេលណា?

រឿន ៖ តាំងពីយើងចូលមកជំរំ៨៥មកវិញ តាំងពីឆ្នាំ៨៥មកវិញៗ

ឃុនលី ៖ ឆ្នាំ៩០មកវិញ?

រឿន ៖ ៨៥ ឆ្នាំ៩០មិនទាន់មានកាប់ ។

ឈុនលី ៖ ប៉ុន្តែឆ្នាំ៩០បានយើងមកវិញ?

រឿន ៖ ចាំ!

ឈុនលី ៖ ដល់ពេលយើងមកវិញបាននាំគ្នាកាប់?

រឿន ៖ ៨៥ កាលពី៨៥កាលនោះគេធ្វើតាំងពី៨៥មក អ្នកគេធ្វើ ។

ឈុនលី ៖ កាប់លក់ម៉ង?

រឿន ៖ គេកាប់លក់ ។

ឈុនលី ៖ លក់ឲ្យខាងណា?

រឿន ៖ ថៃ ។

ឈុនលី ៖ គេឲ្យកាប់ដែរ?

រឿន ៖ ដូចគ្នាអ្នកណាឃាត់ផងជំនាន់នោះ មានដែលឃើញអ្នកណាឃាត់ផង ឃើញតែគេធ្វើ ។

ឈុនលី ៖ ហើយចឹងកាលនឹងដូចថាឆ្នាំ៩០ជាងកូនមីងអាយុប៉ុន្មាន កូនបង?

រឿន ៖ ឆ្នាំ៩០មីងបងអាយុ១៥ ១៦ឆ្នាំទេដឹង កើតឆ្នាំ៨២ ។

ឈុនលី ៖ ហើយគាត់បានចូលរៀន?

រឿន ៖ រៀនៗជំនាន់ខ្មែរក្រហមបង្រៀន ។

ឈុនលី ៖ ខ្មែរក្រហមបង្រៀន?

រឿន ៖ ចាំ!

ឈុនលី ៖ នៅសាលានៅណា?

រឿន ៖ សាលានៅម៉ាឡៃនឹងដដែល រៀនបានថ្នាក់ទី៦ ៗ ខ្មែរក្រហម ។

ឈុនលី ៖ កាលនោះមានសាលាដែរ?

រឿន ៖ មានទៅនៅដីថៃក៏មានសាលាទៅណាក៏មានសាលារៀនដែរ មានទាំងអស់អត់ៗទេ សាលារៀន ។

ឈុនលី ៖ គ្រូគេនឹងខាងខ្មែរក្រហមដែរ?

រឿន ៖ ចាំ! ខ្មែរក្រហម ។

ឈុនលី ៖ គ្រូដែលរត់មកជាមួយគ្នានឹង?

រឿន ៖ រត់មកជាមួយគ្នានឹង ។

ឈុនលី ៖ ចឹងពេលមកដល់នឹងគេបង្កើតឲ្យមានសាលារៀន?

រឿន ៖ ចាំ! បង្កើតឲ្យមានសាលារៀន មានមន្ទីរពេទ្យចឹងទាំងអស់ អត់មានពិបាក ។

ឃុនលី ៖ បើគិតទៅឆ្នាំប៉ុន្មាន ៩០ៗជាង?

រឿន ៖ យី! ឆ្នាំ មើលយើងរត់មក ។

ឃុនលី ៖ អាយុធំហើយ?

រឿន ៖ ធំហើយ ។

ឃុនលី ៖ ផ្តាច់ខ្លួនហើយនៅ?

រឿន ៖ មិនដឹងម៉េចទេ មិនដឹងផ្តាច់ដឹងម៉េច មើលកូនការហើយ ខ្ញុំការហើយឆ្នាំ៨២មានម៉ង មានកូននឹងកើតមកសាលារៀនគេមានរហូតម៉ង ។ និយាយទៅតាំងពីរត់មក មានរហូតសាលារៀន មីងក៏បានរៀនចេះខ្មែរក្រហមនឹងដែរ ។

ឃុនលី ៖ ចឹង?

រឿន ៖ ចា៎! មីងរៀនហ្នឹង ។

ឃុនលី ៖ គេដាក់ថាសាលាម៉ាឡៃចឹង?

រឿន ៖ ចា៎! សាលានៅម៉ាឡៃចឹងម៉ង ។

ឃុនលី ៖ មីងរត់មកដំបូងក្រែង ៧៩?

រឿន ៖ ៧៩ហ្នឹងរត់មកនៅបានប៉ុន្មានខែ គឺគេរៀបរាយមានសាលារៀនរហូត អត់មានអត់ទេ សាលារៀន ។

ឃុនលី ៖ នៅកន្លែងណាសាលារៀននឹង ឥឡូវ?

រឿន ៖ សាលានឹងនៅនេះភូមិដូង ។

ឃុនលី ៖ រាល់ថ្ងៃនឹងនៅដែរ?

រឿន ៖ ឥឡូវនឹងអត់មានទេ ទៅនៅនោះអស់ហើយ ទៅនៅក្រោយសាលាស្រុកទាំងអស់ ។

ឃុនលី ៖ បើគិតទៅភូមិដូងនេះធំណាស់ចឹង?

រឿន ៖ ធំ សាលារៀននឹងនៅជិតមន្ទីរក្នុង ភូមិដូង ។

ឃុនលី ៖ ចុះដូចមីងដឹងថាពីដំបូងមក ពេលដែលមីងមកនៅភ្នាមនឹង ស្រុកនឹងគេហៅស្រុកម៉ាឡៃ?

រឿន ៖ ហ្នឹងហើយស្រុកម៉ាឡៃ ភ្នំនឹងគេហៅភ្នំម៉ាឡៃម៉ង គេហៅស្រុកម៉ាឡៃ ។

ឃុនលី ៖ មីងថាមកដល់ពេលនឹងគេហៅតំបន់១០២?

រឿន ៖ ដំបូង១០២ ប៉ុនដល់ស្រុកម៉ាឡៃកើតនៅឆ្នាំប៉ុន្មានទេ នេះគេហៅស្រុកម៉ាឡៃ ។

ឃុនលី ៖ តែមកនៅភ្នាមគេដឹងថាមានឈ្មោះម៉ាឡៃនឹងម៉ង?

រឿន ៖ ដឹង គេថាមានភ្នំម៉ាឡៃ គេនិយាយភ្នំម៉ាឡៃចឹង ប៉ុនអត់ទាន់មានស្រុកម៉ាឡៃទេ មានតំបន់ ១០២ម៉ង ។

ឈុនលី ៖ តែដល់សាលារៀន គេដាក់សាលារៀនម៉ាឡៃ?

រឿន ៖ ចា៎! ដល់ក្រោយឡើងគេដាក់នៅម៉ាឡៃ ពីមុនក៏សាលារៀន១០២ដូចគ្នាដែរជំនាន់មីងរៀន នោះ ។

ឈុនលី ៖ សាលារៀន១០២?

រឿន ៖ ចា៎! នៅ១០២ហ្នឹងទាំងអស់ ។

ឈុនលី ៖ កាលនឹងមីងអាយុប៉ុន្មានចុះបានចូលរៀន?

រឿន ៖ មីងអាយុ១៧ ១៨ឆ្នាំហើយរៀននោះ អានឹងនារីពួកពេទ្យនឹងចូលរៀនទាំងអស់ ដូចថាអ្នកអត់ចេះអក្សរចឹងគេឲ្យដាំបាយនៅពេទ្យ ដាំបាយឲ្យអ្នកជម្ងឺរួចហើយ រៀបបាយអ្នកជម្ងឺហើយចឹង ដល់ម៉ោង១១ទៅរៀន រៀនម៉ោង២ចេញចាប់ផ្ដើមដាំបាយទៀតហើយ ដាំបាយឲ្យអ្នកជម្ងឺ រៀនបានប៉ុន្មានម៉ោង ។

ឈុនលី ៖ ឆ្នាំ៨០?

រឿន ៖ ចា៎! ឆ្នាំ៨០ ។

ឈុនលី ៖ រៀនបានប៉ុន្មានឆ្នាំ?

រឿន ៖ អឺ! រៀនមិនបានយូរទេ ដូចថារៀនចឹងថ្ងៃណាគេអត់មានបញ្ហា ដូចថាទ័ពគេអត់វៃចឹងយើងរៀនទៅ ពេលណាទ័ពគេរវល់ចឹង ។

ឈុនលី ៖ យើងរត់?

រឿន ៖ យើងអត់រត់ទេ នៅកន្លែងនឹងអត់រត់ទេ ដូចថាពេលដែលវៃគ្នាមានរបួសមានអីច្រើន គេឲ្យជួយធ្វើគ្នា យើងអត់បានទៅរៀននឹងគេ ។ ចឹងមានបញ្ហាចឹង ផ្អាករៀនសិនទៅ ។

ឈុនលី ៖ បើគិតទៅគេរៀនពីអីគេ?

រឿន ៖ រៀនពីយើងដូចថាអ្នកធ្វើគ្រូអង់គ្លេស គេរៀនអង់គ្លេសចឹងទៅ ។

ឈុនលី ៖ មានអង់គ្លេសទៀត?

រឿន ៖ មានគ្រូអង់គ្លេសចឹងទៅ យើងអត់ចេះអក្សរខ្មែរ យើងរៀនអក្សរខ្មែរចឹងទៅ ។

ឈុនលី ៖ ជំនាន់នឹងមានអង់គ្លេស?

រឿន ៖ មានតើ មានអ្នកគេរៀនបារាំងរៀនអីគេរៀនទៅ ។

ឈុនលី ៖ រៀនបារាំង រៀនអង់គ្លេស រៀនខ្មែរ?

រឿន ៖ ចា៎!

ឈុនលី ៖ ហើយបើគិតទៅអ្នកចូលរៀនច្រើននាក់?

រឿន ៖ ទាំងអស់ មីង។អត់ចេះអក្សរក៏រៀនដែរ ទាំងស្រីទាំងប្រុស ទ័ពក៏រៀន ។

ឈុនលី ៖ មីងចាំឈ្មោះអ្នកគ្រូៗរបស់មីង?

រឿន ៖ គ្រូរបស់ខ្ញុំៗចាំឈ្មោះតើ បងរីម ឥឡូវគាត់នៅស្រុកអស់ហើយ ។

ឈុនលី ៖ ស្រុកណា?

រឿន ៖ នៅកំពត ។

ឈុនលី ៖ គាត់ទៅពេលណា?

រឿន ៖ គាត់ទៅតាំងពីជំនាន់ចេញពីជំរំមកគាត់ទៅ ។

ឈុនលី ៖ ចឹងគាត់ចេញចូលទៅហើយ ៩០ក្រែងនៅសង្គ្រាមតើ ពេលយើងមកពីថៃ?

រឿន ៖ នៅសង្គ្រាម គាត់នៅតាមដីថៃ ចេញចូល គេនៅតាមផ្លូវរយៈថៃ ជំនាន់គេអ្នកចេះៗ ។

ឈុនលី ៖ គេអត់ចាប់?

រឿន ៖ អត់ចាប់ទេ គេអ្នកចេះៗគេចេញអស់ គ្រូអង់គ្លេស គ្រូបារាំងអីនៅនេះគេចេញអស់ ចូលជំរំទៅគេចេញអស់អត់មានអ្នកណានៅ ។ គេទៅដូចថាគេមានខ្សែរយៈគេទៅប្រាវៗ គេចេញទៅអស់ ។ ហើយដល់ចឹងចេះឡើងតាមនឹងទៀតទៅគ្រូៗនោះ ។

ឈុនលី ៖ ចុះដល់ពេលក្រោយសមាហរណកម្មនឹង មីងនៅធ្វើពេទ្យដដែល?

រឿន ៖ ចាំ! នៅដដែល ។

ឈុនលី ៖ ហើយបើតាមនិយាយដល់ពេលក្រោយសមាហរណកម្មហើយចឹង ដូចថាការរស់នៅរបស់យើងស្រួលជាងពីមុន ឬមួយក៏ម៉េច?

រឿន ៖ វាស្រួលជាងពីមុន យើងអត់ពិបាកគិតគូរថាភ័យចេះចុះ ដូចថាយើងវាស្រួលហើយវាសន្តិភាពហើយ វាលែងអីទាំងអស់គ្នា ចេះរកបានធម្មតាហើយ ចេះហ៊ានដើររកនេះរកនោះ ទៅចំការទៅស្រែចឹងទៅ ។ ចេញពីព្យាបាលទៅកាប់ព្រៃកាប់អីចឹងទៅ លែងខ្លាចហើយ ។ កាលដែលយើងមិនទាន់សមាហរណកម្មស្រួលសុខ ស្រួលគ្នាមិនហ៊ានចេញទៅណាទេ ។

ឈុនលី ៖ ពិបាកអីខ្លះបើគិតទៅ?

រឿន ៖ ខ្លាចតែរត់ម៉ង ពិបាកខ្លាចតែរត់ បើហូបចុកអីអត់អីខ្លាចតែរត់ ព្រោះឆ្លងកាត់អាររត់ច្រើនពេក នៅផ្ទះហើយរត់២-៣សារ ។

ឈុនលី ៖ ហើយប៉ុន្តែគ្រាន់ថារបបនឹងគេមានហូបចុកអីគ្រប់គ្រាន់?

រឿន ៖ ហូបមាន ជំនាន់នឹងហូបគេបើកឲ្យហូបគ្រប់គ្រាន់ ។

ឈុនលី ៖ ចុះដល់ពេលក្រោយមកមានការខ្វះខាតអីជាងលើកមុន?

រឿន ៖ ដែលដល់ពេលក្រោយពីផ្តាច់ខ្លួនហើយនឹងខ្វះដែលនឹង ។

ឃុនលី ៖ ហើយដល់ពេលខ្វះចឹង មីងចង់ដូចថារស់នៅក្នុងរបបពីមុនមក ដោយសារការហូបចុកយើងខ្វះខាត អត់ដូចលើកមុនមានរបបស្រាប់ៗអីចឹង?

រឿន ៖ ទេ! ដូចថាជំនាន់អារបបស្រាប់ៗនឹងវាម្យ៉ាងវាដូចថាវាស្រួល វាអត់មានបញ្ហា យើងអត់ទៅណាចោលទៅណាចោលផ្ទះ អត់មានចោរមានអី ៗ ដល់ពេលយើងរៀបចំយើងស្រួលបួលហើយចឹងទៅ ដូចថាយើងរកបានអីតិចនឹង យើងចេះខ្លាចដែរ យើងខ្លាចរឿងចោរ បើអត់មានបញ្ហាអីទេ មិនខ្លាចទេ ខ្លាចរឿងចោរម៉ាមុខ ៗ តែបើជំនាន់ខ្មែរក្រហមអត់ខ្លាច ដូចថាទៅមើលបុរាណថៃចឹងទៅស្ងាត់ភូមិអស់រលីង អត់មានអ្នកណានៅទេ អត់ចេះបាត់ទេ ៗ

ឃុនលី ៖ បើគិតទៅសុវត្ថិភាពខាងជំនាន់នោះស្រួលដាង?

រឿន ៖ ស្រួល តែមីងមិនដែលឆ្លងកាត់ណា មីងដឹងថាមីងរត់មកនឹងដឹងវាស្រួលម៉ង ហើយមិនដែលមានអ្នកណាចាប់អ្នកណាចង់ធ្វើបាបអីមិនដែលទេ ៗ

ឃុនលី ៖ ចុះបើប្រៀបធៀបមកសម័យឥឡូវនេះ?

រឿន ៖ បើមកនៅឥឡូវនេះលែងនិយាយយើងរកតាមសេរីខ្លួនយើងហើយ ធ្វើម៉េចក៏បានហើយ ប៉ុនខ្លាចតែរឿងចោរប៉ុននឹងឯង បើថាដូចមុនទៀតវាលែងដូចមុនហើយ វាស្រួលហើយ ៗ យើងចង់បានអីក៏បាន មុនយើងមានបានអីជំនាន់របបបើកហូបគ្មានបានហូប ៗ

ឃុនលី ៖ មីងថាតាហុងនឹងដឹកនាំតំបន់នឹងម៉ង?

រឿន ៖ ចា៎! ដឹកនាំតំបន់នឹង ៗ

ឃុនលី ៖ តំបន់១០៧?

រឿន ៖ ចា៎!

ឃុនលី ៖ ហើយចុះមីងមានដឹងទេថា ដូចថាប្រជាជនចាស់ដែលគាត់រស់នៅតំបន់នឹងម៉ងមានទេ អាខ្ទង់ឆ្នាំជំនាន់៣ឆ្នាំ មានអត់ប្រជាជនរស់នៅអត់តំបន់នឹង?

រឿន ៖ អូ! អត់មានទេ នៅកន្លែងនេះទេ មានតែព្រៃសុទ្ធមកតែព្រៃ ៗ

ឃុនលី ៖ ចុះតំបន់ខាងមុខទៀត ដូចម្តុំខ្លាងរាប់?

រឿន ៖ អត់មានទេ ព្រៃចូលមិនចុះម៉ង ៗ ខ្ញុំចេញពីបវេលមកម៉ង គឺព្រៃប្រោកអត់ដែលមានឃើញជួបមនុស្សមួយទេ មានតែទ័ពគេនាំមុខចឹងគេប្រាប់ថាឥឡូវផ្លូវនេះចេញទៅនឹងគេ ចេះមកតាមគេប្រាប់ចឹងទៅ អត់ដែលឃើញមានផ្ទះប្រជាជន ៗ

ឃុនលី ៖ ហើយដល់ពេលយើងមក ក៏អត់មានជួបអ្នកស្រុកនឹងដែរ?

រឿន ៖ អត់ ៗ

ឃុនលី ៖ សុទ្ធតែអ្នកថ្មី?

រឿន ៖ ចា៎! សុទ្ធតែមកដូចគ្នាចឹង តែដល់ជិតដល់មាត់ដីថៃឆ្ងងអូរចឹង គេថាដល់ថៃឲ្យហើយត្រៀមមានអីវ៉ាន់តិចតួចប្រយ័ត្នថៃវាខ្វេសយកអស់ហើយបើមានមាសមានអីជំនាន់នោះ៣ឆ្នាំ មានអ្នករត់យកមកនោះ ។ ថាចឹងទៅអ្នកមាន ប្រពន្ធមេឃុំមេអីចឹងគាត់មានគំនិតទុកនោះ គាត់មានគាត់លាក់គាត់អី ដល់ចូលដីថៃវារើមែន គេសុំឆែក ។

ឈុនលី ៖ អានឹង៨៥?

រឿន ៖ អត់ទេ ជំនាន់យើងរត់៧៩ ។

ឈុនលី ៖ មានអ្នករត់ទៅដល់ថៃភ្លាមដែរ?

រឿន ៖ ពួកខ្ញុំនឹងអីរត់មកចូលដីថៃប៉ុកម៉ាសារ ។

ឈុនលី ៖ ៧៩?

រឿន ៖ ចា៎! រត់ទៅចូលបន្ទាយទាហាននៅខ្លែមនោះ ។

ឈុនលី ៖ នៅខ្លែម ។

រឿន ៖ ចា៎! មានតើ ។

ឈុនលី ៖ ពេលចូលទៅនៅកន្លែងណា?

រឿន ៖ ទៅនៅបន្ទាយទាហានម៉ង គេឲ្យទៅនៅបន្ទាយនឹងមកនៅទាំងអស់ ។

ឈុនលី ៖ បន្ទាយទាហានរបស់ខ្មែរ ប៉ុននៅលើដីថៃ?

រឿន ៖ នៅដីថៃចូលដីថៃ ។

ឈុនលី ៖ បន្ទាយអីគេអានឹង?

រឿន ៖ បន្ទាយខ្លែមនឹងម៉ង គេហៅខ្លែមដីថៃ ។

ឈុនលី ៖ សព្វថ្ងៃក្រែងខ្លែមរបស់យើង?

រឿន ៖ ខ្លែមមានរបស់យើងម៉ាចំហៀង កាលជំនាន់នោះតែនៅដីថៃម៉ាចំហៀង គេហៅខ្លែមដែរបន្ទាយខ្លែម ។

ឈុនលី ៖ រហូតដល់ឥឡូវគេហៅចឹងអត់?

រឿន ៖ ឥឡូវមិនដឹងម៉េចខាងខ្លែមនឹង ដឹងម៉េចប៉ុនដឹងយើងហៅខ្លែម ប៉ុនផ្សារថៃនឹងដឹងគេហៅផ្សារអីដែរ មីងមិនដែលទៅដែរ ។

ឈុនលី ៖ ហើយដល់ពេលយើងទៅនៅដីថៃភ្លាមនឹង នៅយូរទេ បានត្រឡប់មកវិញ?

រឿន ៖ នៅយូរដែរ ៨-១០-២០ថ្ងៃដែរនឹង បានហើយដល់ទ័ពប្រាប់ថាឥឡូវមកនៅដីយើងវិញអត់អីទេ ក៏មកវិញមកៗនៅដីយើង ។ រត់ជំបូងសុទ្ធតែចូលភ្លីបៗដល់ដីថៃហើយ តែវាអត់ឃើញធ្វើបាបអីដែរ ។

ឈុនលី ៖ ចុះមីងដូចថាមានមីងធ្វើការនៅពេទ្យចឹង មានអគ្គភាពពេទ្យ ហើយក្រៅពីនឹងមានអគ្គភាពអីទៀតទៅ?

រឿន ៖ មានអគ្គភាពពេទ្យដូចថាពេទ្យមានពេទ្យពិសោធន៍ៗចឹង អគ្គភាពដឹកជញ្ជូនៗទៅ ។

ឈុនលី ៖ មានដឹកជញ្ជូន?

រឿន ៖ ចា៎! មានដឹកជញ្ជូន នារីដឹកជញ្ជូន ។

ឈុនលី ៖ ហើយអីទៀត?

រឿន ៖ ដូចមានតែប៉ុននឹង ។

ឈុនលី ៖ ចុះបើតាមខ្ញុំដឹងនារីដឹកជញ្ជូនពេលដែលរៀបការហើយ អត់ទៅធ្វើការទៀតទេ?

រឿន ៖ អត់ទេ ។

ឈុនលី ៖ តែចំពោះនារីពេទ្យវិញ?

រឿន ៖ ពេទ្យអត់ដែរ ពេទ្យនៅធ្វើពេទ្យ ។

ឈុនលី ៖ ទោះបីការហើយក៏ដោយ?

រឿន ៖ ចា៎! ការហើយមានកូនក៏នៅតែធ្វើអត់មានដែលចេញទៅណា ។

ឈុនលី ៖ ម៉េចក៏ខុសគ្នា?

រឿន ៖ ទេ! ដឹកជញ្ជូនធ្ងន់ទៅម៉េចរួច មានផ្ទៃពោះមានអីទៅមិនកើតទេ ។

ឈុនលី ៖ ជញ្ជូនៗរបៀបម៉េច?

រឿន ៖ ទូលគ្រាប់ ។

ឈុនលី ៖ ទូលម៉ិង?

រឿន ៖ ទូលគ្រាប់ ទូលអង្ករយកទៅឲ្យទ័ពនៅមុខ ។

ឈុនលី ៖ ដើរឆ្ងាយៗ?

រឿន ៖ ឆ្ងាយសមរភូមិណា យកឲ្យគេនឹង ។

ឈុនលី ៖ ដូចម៉ុំខ្លាំងរាប់?

រឿន ៖ ចា៎!ទៅខ្លាំងរាប់ទៅអីចឹង ឆ្ងាយ ។ បើដូចពេទ្យនេះ អត់មានដើរទៅណា នៅតែព្យាបាលមើលអ្នកជម្ងឺចឹង ពោះធំពោះអីធ្វើបានទាំងអស់ ។ អានឹងហូបបាយរួមទាំងអ្នកជម្ងឺ ទាំងពេទ្យ ។

ឈុនលី ៖ ហូបគ្រប់គ្រាន់?

រឿន ៖ គ្រប់ដាំបាយពេញៗខ្ទះ អង្ករពេញៗឃ្លាំង កាកបាទដឹកមក ។

ឈុនលី ៖ ចឹងទោះបីជាចាញ់ ឬមួយក៏សង្គ្រាមចឹង ក៏អត់មានអ្នកស្លាប់ច្រើនដែរ?

រឿន ៖ អត់សូវមានទេ ។

ឈុនលី ៖ ហេតុអីបានចឹង?

រឿន ៖ វាមានហូបគ្រប់គ្រាន់ ថ្នាំពេទ្យ ក៏គ្រប់គ្រាន់ដែរឥឡូវ កាកបាទជំនួយថ្នាំគ្រប់មកខ្វះ ។

ឈុនលី ៖ បើគិតទៅក្នុងអគ្គភាពពេទ្យមានប៉ុន្មាននាក់ទៅកាលនឹង?

រឿន ៖ មាន៤០ ៗ នាក់ដំបូង ។

ឈុនលី ៖ ពេលនឹងមីងចូលនៅ?

រឿន ៖ មីងមកៗ ថែម៥ នាក់នឹង បាន៤០ នាក់ ។

ឈុនលី ៖ ចឹងដំបូងមាន៣៥ ?

រឿន ៖ ចា៎! គេមានតែ៣៥ ដល់ចឹងវាខ្វះ ។ ប្រជាជនក៏ឈឺច្រើនរបួសក៏វាច្រើនដែរ ខ្វះដល់ខ្វះមីង មកៗ ព្រោះអ៊ំថុន គាត់ប្រធានមន្ទីរកន្លែងពិសោធន៍នឹង គាត់រើសៗ មកៗ ក៏មកនៅនឹង ។ ប៉ុន មីងមិនចេះអក្សរទេ ។

ឈុនលី ៖ ហើយចុះពេលមីងរត់មកនឹង ហើយចុះឪពុកម្តាយបងប្អូន ម្តាយហើយនឹងបងប្អូន គាត់ដឹងថា មីងរត់មកនេះ?

រឿន ៖ អត់ដឹង ។

ឈុនលី ៖ ពេលណាបានគាត់ដឹង?

រឿន ៖ គាត់ដឹងទើបនេះដែលយើងសម្តេចហ៊ុនសែនមកហើយនេះ ។

ឈុនលី ៖ ៩៦ ?

រឿន ៖ ហ្នឹងហើយ សម្តេចហ៊ុនសែនមករៀបចំស្រួលបួលនឹងបានខ្ញុំផ្ញើរូបថតទៅជាមួយ ។

ឈុនលី ៖ ចុះពេលបោះឆ្នោតនឹង ក្រែងមីងថាផ្តាច់ខ្លួនហើយ?

រឿន ៖ ចុះហ៊ុនសែនមក មិនទាន់បោះឆ្នោតទេណា ។

ឈុនលី ៖ បោះឆ្នោតហើយតើ ហ៊ុនសែនមក៩៧ ហើយបោះឆ្នោតឆ្នាំ៩៣?

រឿន ៖ យី! មិនទេ ដូចមិនទាន់បោះឆ្នោត ខ្ញុំមិនដែលដឹងបោះឆ្នោត ហ៊ុនសែនចុះមកនៅនឹងវត្ត ។

ឈុនលី ៖ អ៊ុនគាត់មក កាលនឹងអ៊ុនគាត់មកនៅ?

រឿន ៖ មកហើយអ៊ុនគាត់មក ហើយហ៊ុនសែនជិះកាប៉ាល់ហោះមកចុះនៅនឹងវត្តនេះ យកអំណោយ មកចែកច្រើនណាស់ ហើយដល់ក្រោយមកបានបោះឆ្នោត ។

ឈុនលី ៖ ហ៎!មីងបោះឆ្នោតមុន?

រឿន ៖ ទេ! បោះមុននោះ ឯងក្នុងបោះហើយ ពួកខ្ញុំអត់មានបោះទេ ។

ឈុនលី ៖ ពេលនឹងអ៊ុនគាត់មក?

រឿន :	ចាំ!ឯងនឹងបោះៗ នេះអត់មានបោះទេ នេះទើបបោះបានប៉ុន្មានឆ្នាំនេះទេ ឯក្នុងបោះនេះអត់ ។

ឈុនលី : ចឹងប៉ុន្តែម៉េចដឹងអ៊ុនគាត់មក?

រឿន :	ដឹង គេថាជំនាន់អ៊ុនគាត់មកៗទ័ពនិយាយ ពូទ័ពនិយាយថាជំនាន់អ៊ុនគាត់នឹង ។

ឈុនលី : អានឹង៩៣ហើយ?

រឿន :	ហ្នឹងហើយ ។

ឈុនលី : ហើយខាងក្នុងគេបោះឆ្នោត?

រឿន :	ចាំ! ហ្នឹងបោះឆ្នោត នេះនៅ ។

ឈុនលី : ប៉ុន្តែកាលនឹងបងប្អូនអត់ទាន់ដឹងដំណឹង?

រឿន :	អត់ទាន់ដឹង ដល់ពេលថាដឹងម៉េចគេចេញចូលបាន មីងអត់ទាន់មានបាននេះទេ នឹកឃើញស្រុកឆ្ងាយមិនហ៊ានទេ ខ្លាចគេយករូបថតអីទៅចោលមិនហ៊ានទេៗ ដល់ជំនាន់សម្តេចហ៊ុនសែន មកចែកអំណោយហើយនឹង បានមានអ្នកស្រុកនឹងចេញចូលផ្ញើរូបថតទៅបានគាត់ដឹង

ឈុនលី : ដល់ពេលគាត់ដឹងទៅម៉េចទៅ?

រឿន :	គាត់ដឹងគាត់មក ។

ឈុនលី : ខួងឆ្នាំណាដែលគាត់មកដំបូង?

រឿន :	កាលសម្តេចមកហើយនឹង ៩៦ ។

ឈុនលី : ៩៧?

រឿន :	អឺ! ៩៧នឹងគាត់មក បងប្រុសខ្ញុំគាត់មក២នាក់ម៉ែ គាត់មកចឹង ៩៧គាត់មកចឹង ដល់ពេល ៩៨ខ្ញុំទៅ ។

ឈុនលី : ៩៨ទៅ?

រឿន :	ចាំ!

ឈុនលី : ដល់ពេលទៅម៉េចទៅ?

រឿន :	ទៅដល់វេទនាណាស់ ពុលឡាន ហើយកូននេះនៅតូចបីកូននេះ ។

ឈុនលី : មានកូនពៅហើយ?

រឿន :	ចាំ! ហ្នឹងកូនពៅ ។

ឈុនលី : កាលនឹងមីងបានប៉ុន្មាននាក់?

រឿន :	កូន៤ ។

ឈុនលី : នាំទៅទាំងអស់?

រឿន ៖ ទាំងអស់ ទៅនៅតូចៗ អត់ស្គាល់លុយខ្មែរយើង ទៅលុយគិតទៅលុយម៉ាម៉ឺនបាតទៅចាយ នៅត្រឹមភ្នំពេញអស់មិនដឹងស្អីណា ។

ឈុនលី ៖ ស្មើនឹងម៉ាលានខ្មែរ ។

រឿន ៖ ចាំ!អត់ស្គាល់លុយនឹង ដូរចុះដូរឡើងចឹងទៅ អត់ស្គាល់លុយខ្មែរម៉េចអីម៉េច អាកូនតូចៗនឹង ក៏វាអត់ដឹងស្គាល់តែលុយថៃ ហើយចឹងទៅចាយលុយនឹងអស់មកវិញបាន តែម៉ាជិះឡានមក ដល់ផ្ទះវិញម៉ាម៉ឺនបាតមិនដឹងណា ។

ឈុនលី ៖ ហើយពេលទៅដល់ចឹង អ្នកស្រុកអ្នកភូមិគេភ្ញាក់ផ្អើលទេ?

រឿន ៖ ភ្ញាក់ផ្អើល ទៅដល់អ្នកស្រុក ទៅដល់រកផ្ទះមិនឃើញទៀត សួរគេតាមឡានសួរថាពូឯង ស្គាល់ផ្សារកំពង់ជ្រៃអត់ គាត់ថាគាត់ស្គាល់គាត់នៅផ្សារកំពង់ជ្រៃ ។ ខ្ញុំសួរថាពូឯងស្គាល់ភ្នំ រន្ទះអត់ គាត់ថាស្គាល់ ខ្ញុំរត់ឡានទៅនឹង ។

ឈុនលី ៖ ភ្នំរន្ទះ ចឹងមិនមែនភូមិរន្ទះ ភូមិភ្នំរន្ទះ?

រឿន ៖ ចាំ! ភូមិភ្នំរន្ទះ ដល់ទៅដល់ភ្នំពេញម៉ោង៧ៗនៅសួរបញ្ឈាក់ឡាន ខ្លាចគេយកទៅចោលនោះ បើទៅតែម៉ែ ហើយឪអត់ទៅទេ នៅចាំផ្ទះ ។ សួរបញ្ឈាក់ចុះឡើងៗ ឡានគេបេះនៅរ៉េៗ ខ្ញុំថាឥឡូវពូពីនឹងទៅផ្ទះខ្ញុំម៉ង់ពូឯងយកប៉ុន្មាន? គាត់ថា៥០០ គេថា៥០០០ ខ្ញុំថា៥០០០ ខ្ញុំគ្មានលុយពីណា គាត់និយាយម៉ឺននោះ ។ ខ្ញុំថា៥០០០ខ្ញុំអត់មានលុយទេ ។ ខ្ញុំថាខ្ញុំមាន លុយបាត ចឹងបែបស្មើគ្នាចឹង៥០០បាតមក ។ ចឹងខ្ញុំឲ្យ៥០០បាតម៉ោកាំម៉ារីនឹងទៅដល់ផ្ទះ ទៅដល់ផ្ទះល្ងាចហើយ សួរថាផ្ទះមួយណា ខ្ញុំថាខ្ញុំអត់ដឹងផ្ទះនៅកន្លែងណា កាលពីខ្ញុំនៅជំនាន់ ខ្ញុំនៅផ្ទះនៅជើងភ្នំ ដល់ចឹងឥឡូវគេធ្វើថ្មីចាស់ក្រោម ។

ឈុនលី ៖ សួរម្ដាយមីងឈ្មោះអី?

រឿន ៖ ម៉ែខ្ញុំឈ្មោះរិត ។ ទៅដល់ចុះសួរកន្លែងគេម៉ាស៊ីនស្រូវនឹង ពូៗឯងស្គាល់ផ្ទះយាយរិតអត់ ថាយាយរិតណា តាមីងណា គេថាអូ!នៅនោះចង្អុរទៀតនៅនោះ ជិតទៅដល់នឹងមានផ្ទះ មួយខាងជើងផ្លូវ ។ ទៅដល់គ្រាន់ទៅដល់ឈប់មុខផ្ទះឃើញម៉ែដឹកគោៗក៏ចុះ ខ្ញុំថាអូ!នោះម៉ែ ខ្ញុំគ្រាន់តែប្រាប់ថាចឹង ចាស់មកជុំយំ ។

ឈុនលី ៖ ដូចថាគាត់មើលទៅដូចស្រឡាញ់យើង អ្នកជិតខាងអីក៏ដោយ?

រឿន ៖ ចាំ! ទៅដល់ និយាយពីមកអីៗមីងមាមកជាវិស្វរទាំងអស់ គ្មានបានសំរាន្តទេ ទាំងយប់ទាំង ថ្ងៃ ។

ឈុនលី ៖ ចុះគេដឹងថាមីងធ្លាប់នៅជាមួយខ្មែរក្រហម?

រឿន ៖ ដឹងតើ ។

ឈុនលី ៖ គេអត់ខឹងយើងទេចឹង?

រឿន ៖ ទៅដល់គេថាកូនអាពតមកហើយ កូនអាពតថាចេះខ្មែរក្រហម ដល់ហើយខ្ញុំនិយាយលេង ខ្ញុំថាខ្មែរក្រហមដូចគ្នាជំនាន់នឹង សុទ្ធខ្មែរក្រហមណាក៏ខ្មែរក្រហមទៅខ្វាចអីខ្មែរក្រហម ខ្ញុំថាចេះ ខ្ញុំនិយាយលេងជាមួយចាស់ៗ ។

ឈុនលី ៖ ហើយចឹងគាត់ថាម៉េចដែរ?

រឿន ៖ គាត់អត់មានថាអី គាត់ថាអឺ!ស្មានស៊ាប់បាត់អស់ហើយ ។

ឈុនលី ៖ ចុះគាត់និយាយអត់មានខឹងសម្បារអីពីយើង?

រឿន ៖ អត់ខឹងទេ ជំនាន់នឹងគៀរចេញពីស្រុកទាំងអស់ដូចគ្នា ។

ឈុនលី ៖ តែពួកគាត់នៅណា អ្នកជិតខាង ឬក៏បងប្អូន?

រឿន ៖ បងប្អូន

ឈុនលី ៖ ម្តាយមីងនៅណាជំនាន់៣ឆ្នាំ?

រឿន ៖ ៣ឆ្នាំនៅនឹងទាំងអស់ នៅស្រុកកំណើតទាំងអស់ គាត់ថា ខ្ញុំស្លាប់បាត់តាំងពីនឹងហើយ ។

ឈុនលី ៖ ហើយពួកគាត់ធ្វើការងារម៉េចទៅ?

រឿន ៖ ធ្វើស្រែចំការធម្មតា ។

ឈុនលី ៖ គាត់ពិបាកទេ កាលនឹង?

រឿន ៖ គាត់ថាពិបាក ព្វថាគាត់ហូបបាយរួមដែរ ប៉ុនគាត់ថាពិបាកខ្វះមុខខ្វះក្រោយ ។

ឈុនលី ៖ ដល់ពេលមីងឮថាគាត់ថាពិបាកអីចឹង មីងមានអារម្មណ៍ម៉េចទៅដល់យើងធ្លាប់នៅដូចថាស្រួល ចឹង?

រឿន ៖ គាត់សួរខ្ញុំ គាត់ថាកូនឯងទៅនឹងពិបាកអត់? ខ្ញុំថាខ្ញុំអត់ពិបាកទេ ហូបចុកអីៗ គាត់ថាម៉ែនៅនេះពិបាកណាស់ ចែកបាយម៉ាកា គេនិយាយកាគេនិយាយកាៗពីដើមម៉ាកាៗ ហ្នឹងពិបាកហូបណាស់ ម៉ែហូបកន្ទក់ហូបដើមចេកអី គាត់និយាយ ។ ដល់ចឹងស្រក់ទឹកភ្នែក មានស្លាប់ខ្លះដែលតើ បងប្អូន... ។

ឈុនលី ៖ ហើយដល់ពេលចឹង អ្នកជិតខាងគាត់ពិបាកគាត់អីចឹង ហើយឃើញមីងរស់នៅស្រួល ហើយមីងធ្លាប់រស់នៅជាមួយខ្មែរក្រហម គេអត់ខឹងយើងទេ?

រឿន ៖ អត់ខឹងអត់អីផង គាត់ថាគាត់ស្មានតែលំបាកដូចគាត់ដែរ ខ្ញុំថាខ្ញុំអត់លំបាកទេ ខ្ញុំមានហូបចុកបរិបូរ ហើយទៅឃើញសាច់ឈាមយើងធម្មតាចឹង ។

ឈុនលី ៖ ទោះបីជាមីងនៅបាត់ដំបងធ្វើស្រែចំការក៏ហូបចុកគ្រប់ដែរ?

រឿន ៖ ចា៎! ហូបគ្រប់អត់ដែលលំបាក ។

ឈុនលី ៖ កាលនឹងមីងនៅជាប្រជាជនទេ?

រឿន ៖ នៅប្រជាជន នៅតាមកងចល័តនោះ ។

ឈុនលី ៖ ចឹងនិយាយទៅដូចថាមានចូលជាមួយខ្មែរក្រហម ពេលដែលជម្លៀសចេញមក?

រឿន ៖ ចា៎!

ឈុនលី ៖ ឆ្នាំ៧៩?

រឿន ៖ ដូចមិនដែលឃើញលំបាកអីផង ។

ឈុនលី ៖ ហើយដល់ពេលក្រោយមកមីងនៅតែធ្វើពេទ្យដដែល?

រឿន ៖ នៅតែចឹងតាំងពីរត់មកនៅតែចឹងរហូត ប៉ុនមីងមិនសូចចេះអីទេ មីងមិនសូវចេះអក្សរទេ ចេះតិចតួច ។

ឈុនលី ៖ ពេទ្យ ខាងនាទីមីងធ្វើអី?

រឿន ៖ បុគ្គលិកទូទៅ ។

ឈុនលី ៖ មើលជម្ងឺម៉េច?

រឿន ៖ មើលជម្ងឺទូទៅ គ្រុនចាញ់ គ្រុនអីធម្មតា ។

ឈុនលី ៖ យើងអ្នកឲ្យថ្នាំឲ្យអីនឹង?

រឿន ៖ ចា៎! មានដុកទ័រគេបញ្ជាថ្នាំចឹងទៅ យើងអ្នកចែក អ្នកចាក់អីចឹង ។

ឈុនលី ៖ មីងដើរចាក់ថ្នាំតាមផ្ទះអីអត់?

រឿន ៖ អត់ទេ មីងមើលក្នុងមណ្ឌល មីងមិនហ៊ានទេ ព្រោះមីងអត់មានសញ្ញាប័ត្រទេ កាលនោះដែលផ្តាច់ខ្លួនហើយឲ្យទៅរៀន ។ មីងនឹកឃើញថាចាស់ហើយ បើទៅរៀនទៅអត់មានអ្នកណារកអីចិញ្ចឹមកូន ។

ឈុនលី ៖ រៀននៅណា?

រឿន ៖ រៀននៅស្វាយ ហើយដល់គេអ្នកទៅរៀនគេបានសញ្ញាប័ត្រទៅ ហើយមីងអត់ចេះអក្សរផង ចេះអក្សរខ្មែរតិចៗ ។ ហើយទៅរៀនពេទ្យសុទ្ធតែបារាំងសុទ្ធតែអីមីងអត់ចេះ មីងអត់ទៅរៀន ។ ដល់ចឹងអត់ៗសញ្ញាប័ត្រមីងមិនហ៊ានដើរតាមផ្ទះទេ ខ្លាចគ្រោះថ្នាក់ ។

ឈុនលី ៖ មីងធ្វើពេទ្យនឹង មីងស្គាល់មីងខុន?

រឿន ៖ មីងខុនៗនៅខេត្ត?

ឈុនលី ៖ ភូមិហ្នឹងដែរ?

រឿន ៖ ភូមិកណ្តាលនឹង?

ឈុនលី ៖ ចា៎!

រឿន ៖ ស្គាល់តើ

ឈុនលី ៖ ដូចថាកាលនឹងធ្វើការជាមួយគ្នាដែរ?

រឿន ៖ ចាំ!

ឈុនលី ៖ ព្រោះខ្ញុំសួរគាត់ទៅ គាត់ថាគាត់ធ្វើពេទ្យនៅនឹងដែរ ។

រឿន ៖ ចាំ! ពីមុនគាត់ពេទ្យនៅចំការចេក ខុននឹង កាលជំនាន់នឹងនារីៗនោះ ។

ឈុនលី ៖ ចំការចេក មីងថានៅណា?

រឿន ៖ ចំការចេកហ្នឹងឥឡូវនៅគីឡូ១៣នឹង ដល់គាត់មានប្ដីៗគាត់នៅជាមួយខ្ញុំនេះ ដល់គាត់ការមកនៅនេះ ។

ឈុនលី ៖ ពេទ្យដូចគ្នា?

រឿន ៖ ចាំ! ពេទ្យដូចគ្នា ប្ដីគាត់ក៏ពេទ្យដែរ ។

ឈុនលី ៖ ចឹងមកនៅធ្វើការជុំគ្នា?

រឿន ៖ ចាំ! ដល់ពេលការហើយមកនៅនេះជុំគ្នា ។

ឈុនលី ៖ ហើយរស់នៅឥឡូវរហូតដល់ជុំគ្នា?

រឿន ៖ ចាំ! ឥឡូវនៅជុំគ្នា ប្ដីគាត់នៅធ្វើពេទ្យ មីងខុមគាត់ឈប់ហើយ នៅប្ដី ហើយខ្ញុំពូក៏ឈប់ដែរនៅតែខ្ញុំ ។

ឈុនលី ៖ ចុះពូហេតុអីបានគាត់ពិការ?

រឿន ៖ គាត់ទៅកាប់ចំការ ។

ឈុនលី ៖ ដុះមីន?

រឿន ៖ ចាំ! ទៅកាប់ព្រៃ ។

ឈុនលី ៖ ឆ្នាំណា?

រឿន ៖ ឆ្នាំ៩២ ខ្ញុំពោះធំ៧ខែកូន អេ!៩១ទេ ៩១ពោះធំ៧ខែក៏គាត់ទៅព្យាបាលអ្នកជម្ងឺ គាត់ថាគាត់ទៅកាប់ព្រៃបង្អើយតិចទេ អត់ចាំរោងទេថ្ងៃនេះ ។ គាត់មិនបានហូបបាយជងនឹង គាត់ទៅកាប់ព្រៃទាល់ម៉ោង៥ល្ងាចចាំបាត់ៗ ដល់ពូគេថាដុះមីន ខ្ញុំនឹកព្រួយខ្ញុំថាគ្មានពីណាទេមានតែឪវាបាត់ម៉ាថ្ងៃវាស់ល្ងាចហើយ បាយថ្ងៃក៏មិនទាន់មកហូប ។ ដល់ចឹងខ្ញុំប្រាប់ពូៗគាត់ទៅរក ពូពេទ្យនឹងគាត់ទៅរកគាត់វាចេញពីព្រៃមីនមក ។ ដាច់ត្រឹមនេះ គាត់ចងការ៉ូខ្លួនឯងចេញមក ។

ឈុនលី ៖ បើគាត់ពេទ្យ គាត់ដឹង?

រឿន ៖ ចាំ! គាត់ចងការ៉ូខ្លួនឯង ។

ឈុនលី ៖ កាវ៉ូម៉េចទៅ?

រឿន ៖ ខ្សែកន្សែងមួលឲ្យតឹងទៅ គាត់ចងខ្សែកាវ៉ូគេមាន តែដល់យើងអត់ កុនកន្សែងមូលចង។

ឈុនលី ៖ ចងកុំឲ្យហូរឈាម?

រឿន ៖ ចងឃាត់កុំឲ្យហូរឈាម ដល់ចឹងទៅទៅសែងរបួសមកៗ ធ្វើដើងនៅនេះមក ជំនាន់នឹងយើងមកពីដីថៃយ៉ាប់ដែរនឹងវាខ្វះគ្រប់មុខ។

ឈុនលី ៖ អីវ៉ាន់ពេទ្យនឹងក៏ខ្វះខ្វះដែរ?

រឿន ៖ ចាំ! អីវ៉ាន់ពេទ្យនឹងក៏ខ្វះខ្វះដែរ ដល់ចឹងក៏រកខ្យល់ទៅនៅកំរៀង ទៅពេទ្យនៅកំរៀងនឹងទៅដល់ទិញសុទ្ធថ្នាំ អឺ!ទិញឈាមយកទៅដាក់កន្លែងនឹងទៀត មានពេទ្យធំនៅកន្លែងនឹង ពេទ្យលោកតា ជួន ជឿន។

ឈុនលី ៖ មឹងខុសស្រាហ៎ទៅលេងស្រុកកំណើតទេ?

រឿន ៖ មឹងទើបទៅបាន២ដង ប៉ុនម៉ែមកញឹកដែរ ម៉ែមកញឹកកូនមិនសូវទៅទេ កូនពុលឡានពេក។

ឈុនលី ៖ ហើយដល់ពេលទៅអីចឹង បើគិតទៅយើងទៅលេងស្រុកកំណើត យើងនឹកស្រុកអីចឹង?

រឿន ៖ យើងនឹក។

ឈុនលី ៖ ហើយពេលទៅចឹង យើងនឹកនៅនេះជាង?

រឿន ៖ ពេលទៅចឹង ដូចថាស្រុកកំណើតបងប្អូនច្រើនទៅ ដូចថាវាមិនសូវនឹកទេនេះ ប៉ុនផ្ទះយើងចេះបារម្ភពីផ្ទះពីសម្បែងដែរនឹងទៅយូរដែរ ប៉ុនបើថាទៅនោះសប្បាយជាង។

ឈុនលី ៖ នៅនោះសប្បាយជាង?

រឿន ៖ ចាំ! បងប្អូនច្រើន ហើយដូចថាត្រីសាច់អីរកបានហូបធម្មតា នៅនេះហូបរបស់ថៃរបស់ទឹកកកគីមី បន្លែក៏គីមី។

ឈុនលី ៖ ចុះមឹងអត់ចង់ទៅនៅនោះវិញទេ?

រឿន ៖ អត់ទេ ពិបាកនៅណាស់ចង្អៀតណាស់ ដី។

ឈុនលី ៖ ដីចង្អៀត?

រឿន ៖ ដីចង្អៀត នៅនេះវាស្រួលចាប់ដីចាប់អីបាននៅស្រួល។

ឈុនលី ៖ ហើយដល់ពេលចឹង ពេលក្រោយសមាហរណកម្មចឹង យើងសុទ្ធតែធ្លាប់រស់នៅជាមួយគ្នាអីចឹង ក្រោយមកការរាប់អានគ្នាម៉េចដែរ?

រឿន ៖ ធម្មតាដូចពីមុន។

ឈុនលី ៖ ស្រឡាញ់គ្នា?

រឿន ៖ ចាំ! ទោះបីមានអ្នកមកថ្មី មកសង់ផ្ទះថ្មី នៅថ្មី ទិញដីថ្មីនៅក៏ដូចរាប់អានធម្មតា មានបាយសម្លអីប្លែកហុចទៅ បន្ថែមអីហុចគ្នាទៅវិញទៅមកដូចពីមុន ។

ឈុនលី ៖ ចុះដូចថាអ្នកមកនៅថ្មីគេចាប់ផ្តើមមកនៅដំបូងឆ្នាំណា ដែលថាហូរចូលមកបណ្តើរៗ?

រឿន ៖ ហូរចូលមកនឹងតាំងពីជំនាន់ ដែលយើងស្រុះស្រួលគ្នាហើយនឹង សមាហរណកម្មហើយនឹងឃើញមកការផ្តាច់ខ្លួននឹង បេះមកនៅ ។ ផ្ទះមុខនេះអីសុទ្ធតែមកៗគេទិញដីទិញអីនៅ បេះមកនៅជាប់ចឹងទៅ ។ ប៉ុនអត់អីសុទ្ធតែមករាប់អានគ្នាធម្មតាដូចបងប្អូន ។

ឈុនលី ៖ ចឹងគេមកចឹងគេដឹងថាតំបន់នឹង តំបន់ខ្មែរពីមុន ចឹងគេខ្លាច?

រឿន ៖ គាត់ថាអត់ខ្លាចផង គាត់មក មានបងប្អូននៅនេះដែរ ។

ឈុនលី ៖ មានបងប្អូនអតីតខ្មែរក្រហមដែរ?

រឿន ៖ ចាំ! មានបងប្អូននៅនឹង ប្អូនហៅមកថានៅស្រុកពិបាករកស៊ី អត់មានដីមានធ្លីហៅមកចឹងទៅ ឥឡូវគេមកចាប់ដីចាប់បានធូរធាហើយ ។

ឈុនលី ៖ ដូចថាកូនរបស់មីងធ្លាប់រៀននៅសាលា កាលខ្ទង់ឆ្នាំ៨០ជាង ៩០ជាង មីងថាសាលាមីងធ្លាប់រៀន ហើយកូនរៀនដែរ?

រឿន ៖ កូនរៀនដែរ កូនចូលរៀនឆ្នាំ៨៥មីងបងនោះរត់ទៅនៅដីថៃនោះរៀន ចាប់ផ្តើមរៀន ក ខ ពីនឹងមកហើយ ។

ឈុនលី ៖ ចឹងទើបអាយុប៉ុន្មាននឹង?

រឿន ៖ អាយុប៉ុន្មានឆ្នាំនឹង ទើបបេះដើរ មើលវាកើត៨២ ៨៣ ៨៤ ៨៥ទើប៤ឆ្នាំទេ ៤ឆ្នាំគឺចូលទៅរៀនតិចតុបៗនឹង ហើយអ្នកគ្រូបាននឹងឥឡូវគាត់ធ្វើការនៅអង្គការសិទ្ធិមនុស្ស គាត់បង្រៀនទាំងប្តីទាំងប្រពន្ធនឹង ។

ឈុនលី ៖ គាត់នៅណា?

រឿន ៖ ឥឡូវគាត់នៅបាត់ដំបង សុទ្ធកូនសិស្សគាត់ហើយ បង្រៀនដល់អាបងអាប្អូននឹងតូចទៀតនឹង បេះនាំគ្នាទៅនឹង ចុះម៉ែជាប់ធ្វើការៗផងរៀនពេទ្យផង ។

ឈុនលី ៖ មីងបើគិតទៅភាគច្រើនកូនសិស្សដែលរៀននឹង ភាគច្រើនកូនសិស្សដែលរៀននឹងកូនសិស្សក្នុងពេទ្យ ឬក៏អ្នកផ្សេងទៀត?

រឿន ៖ អ្នកផ្សេងក៏រៀន កូនពេទ្យក៏រៀន រៀនទាំងអស់ កូនទ័ពក៏រៀនៗជាទូទៅ ។

ឈុនលី ៖ ប៉ុន្តែបើគិតទៅដូចថានារីដឹកជញ្ជូន កូនគាត់ក៏រៀនដែរ?

រឿន ៖ រៀនៗដូចគ្នា ។

ឈុនលី ៖ អានឹងដោយសារអី ដោយសារយើងអត់មានអ្នកណាមើល ឬយ៉ាងម៉េច?

រឿន ៖ អត់មានអត់អ្នកណាមើលទេ គឺគាត់អ្នកទទួលខុសត្រូវ គាត់គិតគូរឲ្យមានសាលារៀននឹងចិន ម៉ង ហើយយកទៅចិនទៅ គាត់បង្រៀន គាត់មើលចិនទៅ ដល់ម៉ោងវានាំគ្នាចេញមកវិញមក ម៉ែឪក៏ចេញពីធ្វើការ ។

ឈុនលី ៖ ហើយដល់ពេលក្មេងតូចៗអីចឹងចាញ់ដែរ ដល់ពេលឆ្នាំ៨០ជាង?

រឿន ៖ ចាញ់ដែរនឹង ទល់សព្វថ្ងៃក៏នៅមានចាញ់ដែរ ។

ឈុនលី ៖ សព្វថ្ងៃនៅមាន?

រឿន ៖ ចា៎! គ្រុនចាញ់មានអត់ដាច់ទេ គ្រាន់តែវាមានឆ្ការ ដូចថាពីមុន១០០សឹងតែ១០០ ឥឡូវ ១០០មាន១ មាន២អីទេ ។

ឈុនលី ៖ ភាគច្រើនពីតំបន់ណាដែលចាញ់?

រឿន ៖ សព្វថ្ងៃនឹងអ្នកដែលទៅចំការឆ្ងាយ ពីអូរធំពីអីមកវិញ បើអ្នកនៅនេះអត់សូវអីទេ ។

ឈុនលី ៖ អានឹងមកពីអីគេ?

រឿន ៖ មូសខាំ ។

ឈុនលី ៖ ដូចយើងមកដំបូងវាសុទ្ធតែព្រៃ សំបូរមូស?

រឿន ៖ ចាស់ព្រៃសំបូរមូសណាស់ ឥឡូវនេះសំបូរមេរោគរីវ៉ាក់ ស៊ីប្រូលែងសូវមានហើយ ។

ឈុនលី ៖ អានឹងប្រភេទចាញ់ដែរ?

រឿន ៖ ចាញ់អានឹងញាក់ៗអាក្រក់ ញាក់នោះញាក់លែងនិយាយហើយអាវីវ៉ាក់នឹង ចឹងបានមកស្រុកម៉ាឡៃចាស់ៗហាមកូន ហាមប្រយ័ត្នគ្រុនចាញ់ ។

ឈុនលី ៖ ចុះដូចជំនាន់ពាឆ្នាំ មីងប្រាប់ថាមីងជាប្រជាជនធម្មតាដូចគេដូចឯង តើមីងធ្លាប់បានជួយអ្នកណាម្នាក់ធ្វើអំពើល្អ ជួយអ្នកណាម្នាក់អីចឹង?

រឿន ៖ មីងមិនដែលបានជួយអីពីណាផង បើនៅក្មេងៗតូចៗដូចគ្នាមើលគ្នាឯងតាមកងចឹង មិនដែលបានទៅធ្វើអីណាទេ ។

ឈុនលី ៖ ចុះមីងនៅសល់រូបថតចាស់ជំនាន់នឹងទេ?

រឿន ៖ អត់ទេ មីងមិនដែលមានរូបថតផងជំនាន់នឹង ។

ឈុនលី ៖ ម៉េចចឹង?

រឿន ៖ មិនដែលមានទេ មិនដែលស្គាល់រូបថតម៉េចផង ។

ឈុនលី ៖ ចុះក្រោយមកឆ្នាំ៨០ជាងមកនៅនេះ?

រឿន ៖ ហ៊ឺ! អត់ដែលថតទេ អត់ដែលមានថតទេ ។

ឈុនលី ៖ មីងខាងពេទ្យនឹងអត់ដែលមានរូបថតទេ?

រឿន ៖ អត់ទេ ជំនាន់នឹងមិនមានទេ ទើបយើងមកដែលសមាហរណកម្មហើយ ស៊ីប្រាក់ខែរដ្ឋនោះបានចាប់ផ្ដើមមានរូបថតធ្វើអីៗបេះបានមានច ពីមុនមិនដែលមានទេ ។

ឈុនលី ៖ ចឹង?

រឿន ៖ ចា៎!

ឈុនលី ៖ ឧទាហរណ៍ថាយើងថត ឧទាហរណ៍ថាក្នុងកំឡុងពេលខ្ទង់៨០ជាង គេដែលមានកម្មវិធីជប់លៀងអីអត់?

រឿន ៖ មានតើ ប៉ុនមានកម្មវិធីជប់លៀងចឹង ដូចថាមានថតរូបថតបិតនៅកន្លែងការងារចឹងទៅ បើថាឯកជនមួយៗមិនមានទេ ។

ឈុនលី ៖ ចុះដូចរូបថតរួមអីមានទេ?

រឿន ៖ មីងមិនដែលទុកទេ តែមេប្រធានៗគេទុកកន្លែងធ្វើការនឹងទៅ មីងមិនដែលមានទេ ។

ឈុនលី ៖ អានឹងជប់លៀងឧទាហរណ៍ថាដូចកម្មវិធីអីគេ?

រឿន ៖ ជប់លៀងនឹងដូចថាឥឡូវគេធ្វើអីថាបានចឹងទៅ គេនាំគ្នាជប់លៀងហូបអីៗ ។

ឈុនលី ៖ ចុះដូចថាមីងធ្វើការចឹងទៅ ដូចថាមានថ្នាក់ដឹកនាំគេមកមើល?

រឿន ៖ អត់ ។

ឈុនលី ៖ គេអត់មកពិនិត្យការងារយើង?

រឿន ៖ ចា៎! អត់ទេ មានតែដូចកាកបាតជំនួយមីងមកកាកបាតជំនួយមានកាកបាត ។

ឈុនលី ៖ គេមកមើល?

រឿន ៖ ចា៎! គេមកមើលដូចប្រចាំថ្ងៃនឹងមានដុកទ័រចុះមកមើលប្រចាំថ្ងៃ ប៉ុន្តែក្នុងម៉ោអាទិត្យមានដុកទ័រធំមកម្ដង ។ មកម្ដងចឹងគាត់មកមើលដូចថាខ្វះថ្នាំ ខ្វះអីអ្នកជម្ងឺការថែទាំម៉េចៗចឹង គាត់ឲ្យយោបល់ហើយ ជាមួយលោកតា ជួន ជឿនហ្នឹង ។

ឈុនលី ៖ លោកតា ជួន ជឿន?

រឿន ៖ ចា៎!

ឈុនលី ៖ គាត់ធ្វើអីគេ?

រឿន ៖ គាត់ពេទ្យ ។

ឈុនលី ៖ ពេទ្យរបៀបម៉េច?

រឿន ៖ ពេទ្យពីមុនលោកតា ជួន ជឿននឹង ខ្ញុំមិនសូវដឹងដែរ ឃើញជំនាន់ខ្មែរក្រហមនឹង គាត់ពេទ្យធំម៉ង ។

ឈុនលី ៖ ប្រធានពេទ្យ?

រឿន ៖ គាត់បង្រៀនខ្មែរក្រហមពេទ្យនឹង នៅប៉ៃលិននៅអីក៏គាត់បង្រៀន លោកតា ជួន ជឿន បង្រៀនពួកខ្ញុំពួកអី ។

ឈុនលី ៖ ចុះឥឡូវគាត់នៅណា លោកតា ជួន ជឿន?

រឿន ៖ ហ៎! លោកតា ជួន ជឿន ស្លាប់បាត់ហើយមិនដឹង ដល់នេះនៅប៉ៃលិន ឥឡូវមិនដែលឃើញមិនដែលនេះ ចាស់ហើយវង្វេងឡើងជំនាន់ខ្មែរក្រហម យោធាដូចថាមានរបួសខ្លាំងបើកពោះបើកអី គាត់មកនឹងវង្វេង ប៉ុន្តែរបួសអីគាត់ធ្វើបានទាំងអស់ គាត់ចាស់មែនទែនហើយ ។

ឈុនលី ៖ តែគាត់ប្រធានគេដែរមើលទៅ គាត់ធំ?

រឿន ៖ គាត់ធំពេទ្យ ពូចាស់ៗគាត់និយាយពីសង្គមគាត់នឹងនៅស្រុកខ្មែរលើគេ ។ ពូចាស់ៗដូចថាពូហុងពូអីគាត់រៀន គាត់និយាយថាមានតាជួន ជឿន ដុកទ័រធំជាងគេនៅស្រុកខ្មែរ ពូគាត់និយាយចឹង ខ្ញុំមិនសូវដឹងដែរ ។

ឈុនលី ៖ ចឹងមីងអត់ដែលដឹងប្រវត្តិគាត់ដែរ ថាគាត់ពីជំនាន់៣ឆ្នាំនៅណា?

រឿន ៖ អត់ដឹងទេ ទើបដឹងរត់មកដែរ គាត់នៅរៀនពេទ្យនឹង បានស្គាល់គាត់ត្រឹមនឹង ហើយមិនដែលស្គាល់ ។

ឈុនលី ៖ អរគុណមីងច្រើន ខ្ញុំដូចអស់សំនួរសួរមីង ។

រឿន ៖ ចា៎! ក្រោយឡើងខ្ញុំចេញពីផ្ទះអ្នកជម្ងឺដាំបាយចឹងទៅ កាប់ទាំងប្តីទាំងប្រពន្ធដើមឈើប៉ុននេះរលំដុតៗស្មើនឹងអីមិនទាន់មកដល់ផ្ទះផង ។

ឈុនលី ៖ អានឹង៩០ជាង?

រឿន ៖ ចា៎! ដុតព្រៃនឹង ហើយមីននិយាយពីមីនៗសុទ្ធមីន៦៩ មីនច្រើនណាស់ ។ ហើយឃើញនេះឆ្អឹងខ្មោចតាមដើមស្រឡៅធំៗ ខ្លះឆ្អឹងនៅផ្ដេកចេះឯងទៅ ។

ឈុនលី ៖ អានឹងម៉េចវិញ ដោយសារអី?

រឿន ៖ អានឹងដឹងម៉េច គេថាក-៥យួនគៀរមកម៉េចទេ ពូគេនិយាយ ។

ឈុនលី ៖ ចាញ់?

រឿន ៖ គ្រូនចាញ់ហើយ ។

ឈុនលី ៖ ឃើញឆ្អឹង?

រឿន ៖ ឆ្អឹងៗខ្មោចឡើងដូចអីចឹង ។

ឈុនលី ៖ ខ្លាច?

រឿន ៖ ទេ! វាធ្លាប់ទៅអត់ខ្លាចទេ បេះកាប់ចឹងទៅ កាប់ទាំងប្ដីទាំងប្រពន្ធតាមគ្រួសារៗកូននៅផ្ទះម៉ែឪ នៅទៅកាប់ចឹងទៅល្ងាចឡើងមកវិញមក ព្រលឹមឡើងធ្វើការហើយចឹងទៅ អ្នកណាចាំវេងចាំទៅ អ្នកណាអត់ចាំទៅកាប់ទាំងអស់គ្នា ទាល់តែឥឡូវ ។

ឈុនលី ៖ ចឹងកាលនឹងលែងខ្លាចលែងអីទៅ?

រឿន ៖ លែងហើយលែងខ្លាចហើយ ជំនាន់នោះចុះថាហើយស្រួលអស់ហើយ ។ កាប់ព្រៃចឹងកាប៉ាល់ហោះមកសម្ដេចហ៊ុន សែនមក នាំគ្នាអូ!បែបសម្ដេចហ៊ុនសែនមកបេះចុះ បេះនាំគ្នានិយាយ ឈប់ប្រាប់ពេញព្រៃនឹងទៅ ។

ឈុនលី ៖ ចុះមីងដូចថាធ្លាប់នៅស្រុកភូមិអីចឹង ដល់ជំនាន់៧៩ចូលក្នុងព្រៃចឹងខ្លាច?

រឿន ៖ ខ្លាច ៧៩ចូលខ្លាចតើ មិនដឹងធ្វើម៉េចយើងត្រូវមកចឹងហើយ មិនដឹងទៅណាទោះបីទៅនោះវិញក៏មិនដឹងទៅវិញធ្វើម៉េចរួច ។

ឈុនលី ៖ ហើយកាលនឹងមីងថាតាម៉ុកមកឃាត់អីចឹង អានឹងនៅណា នៅស្រុកអីគេខេត្តពោធិ៍សាត់?

រឿន ៖ នៅស្រុកលាច ខេត្តពោធិ៍សាត់ ស្រុកលាច ។

ឈុនលី ៖ មកដល់លាច?

រឿន ៖ ចា៎! តាម៉ុក ។

ឈុនលី ៖ ឃុំលាច?

រឿន ៖ ស្រុកលាចហ្នឹងម៉ង គេហៅស្រុកលាចៗ គាត់ថាអត់ឲ្យទៅទេ កុំទៅយួនចាប់យកអស់ហើយរកម៉ែឪមិនឃើញទេ ប៉ុនៗនឹងនោះ គាត់និយាយចឹង នាំគ្នាទៅលិចវិញ ទៅពាយ័ព្យ គាត់បេះមកបាត់ដំបង ។

ឈុនលី ៖ ខាងនឹងគេហៅខាងពាយ័ព្យ?

រឿន ៖ ហ្នឹងហើយមកពាយ័ព្យ មកដល់កោះក្រឡនឹងយួនវ៉ៃរត់បែកគ្នារញ៉េរញ៉ៃ ទម្រាំរកគ្នាឃើញវេទនាដែរនឹង ទម្រាំរត់ម៉ាសារនឹង ។

ឈុនលី ៖ មីងថារត់កាត់អូរដាៗហ្នឹងនៅស្រុកក្រវ៉ាញដែរ ជាជ្រោះ?

រឿន ៖ ចា៎! ជ្រោះ មកកាត់អូរដារនឹងមានផ្លូវឆ្លងគេ ឆ្លងទឹក ពួកខ្ញុំប្រជាជនគាត់បរទេះឆ្លងកាត់អូរដានឹង យប់ភ្លើងឆេះព្រៃចឹងបេះនាំគ្នាទៅហើយ មិនដឹងទៅណាទៅណៃ ពេលណាគេវ៉ៃគ្នាប្រឹងៗបេះនាំគ្នាសំងំស្ងាត់ចឹងទៅ គេឲ្យមកលិចៗទៅ គេឲ្យទៅកើតៗទៅៗបេះរត់ទៅមិនដឹងទៅណាទៅណៃ នៅម៉ាកន្លែងសិន ។ គ្រាន់ដូចថាឥឡូវមកដល់នឹង គេវ៉ៃគ្នាហើយយោធាគេប្រាប់ថាអ្នកមានកូនអត់ទាន់ឲ្យទៅទេ តែរឹងទៅគេយកសម្លាប់ចោលហើយ ។ ហើយដល់ចឹងគាត់ក្រាញនៅម៉ាកន្លែងសិន គាត់អត់ហ៊ានទៅជិតគេ ។

ឈុនលី ៖ ចុះបើគេមកជិតធ្វើម៉េច?

រឿន ៖ ក្តាប់មាត់កូន តែក្មេងជិតនាំនឹងវាអត់កាចដែរ ខ្លាចអត់យំអត់អីទេ គេអត់ឲ្យទៅជិតទេ គេខ្លាចចឹងឯងរឿងមានកូនមានអីមួយៗជិតនាំរត់៧៩ហ្នឹងនោះ ។ តែមិនសូវមានកូនទេ មាន១អ្នកខ្វះទៅឡើងទៅណា ទៅភ្នំណាណែនង្គភ្នំ យកកូនទៅចោលនៅលើភ្នំក៏មាននឹង ។

ឈុនលី ៖ នៅខាងពោធិ៍សាត់នឹង?

រឿន ៖ ចា៎! ពោធិ៍សាត់នឹង អ្នកឡើងភ្នំចោលកូនចោលណាស់ ។

ឈុនលី ៖ ភ្នំអីគេកាលនឹង?

រឿន ៖ ភ្នំក្រវាញ់ ភ្នំអីនឹងក៏មានអ្នកឡើងដែរ ។

ឈុនលី ៖ ក្រវ៉ាញ់?

រឿន ៖ ចា៎!

ឈុនលី ៖ ចាញ់វាប់ហើយ?

រឿន ៖ ចាញ់ ចោលកូននៅនឹងទៀត ថាទុកកូនចោលនៅនឹង មីងៗគាត់និយាយ គាត់ថាចោលកូនដាក់បាយម៉ុំ ហើយដាច់ចិត្តចោល គេអត់ឲ្យរត់តាម ហើយចឹងរត់តាមគេមក ។

ឈុនលី ៖ ចឹងរត់នឹងមានបាយហូបទៀត?

រឿន ៖ រត់មាន អ្នកណាមានៗអ្នកណាអត់ៗ ពួកខ្ញុំអីសុទ្ធតែអង្ករដាក់តែនោះស្ពាយ ។

ឈុនលី ៖ ហើយយើងស្ពាយឆ្នាំងអីទៅ?

រឿន ៖ ស្ពាយឆ្នាំងតែដាក់ពេញៗខ្លួនខោអាវសាក់កាដូស្ពាយពីក្រោយឆ្នាំងយួរ ដល់កន្លែងណាឈប់ទៅ ។

«ចប់»